# របាយការណ៍
# ស្តីពី
# វឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាព
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
# ប្រចាំឆ្នាំ ២០១៤

**អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ខែមករា ឆ្នាំ២០១៥**

# មាតិកា

I. សេចក្តីផ្តើម ........................................ ៣

II. លទ្ធផលសម្រេចបានតាមផ្នែក........................................ ៥

III.បញ្ហាប្រឈម........................................ ៣២

IV. អនុសាសន៍ ........................................ ៣៣

V. សន្និដ្ឋាន........................................ ៣៤

**ឧបសម្ព័ន្ធ៖**

**ឧបសម្ព័ន្ធ ក. សូចនាករសមិទ្ធកម្មគន្លឹះ**

**ឧបសម្ព័ន្ធ ខ. តារាង របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៤**

# I. សេចក្តីផ្តើម

របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១៤ ជារបាយការណ៍ដែលមានលក្ខណៈពិសេសជាងឆ្នាំណាៗទាំងអស់ ព្រោះកំពុងឈានទៅបញ្ចប់ដំណាក់កាលទី២ ឆ្ពោះទៅដំណាក់កាលទី៣ ដែលលទ្ធផលទាំងនេះពិតជាមានសារៈសំខាន់សម្រាប់ឱ្យយើងយល់ដឹងយ៉ាងច្បាស់អំពីស្ថានភាពពិតប្រាកដនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយពុំមើលរំលងលទ្ធផលដែលទទួលបានពីការអនុវត្តនៅឆ្នាំ២០១៣ នោះទេ។ ការតាមដានត្រួតពិនិត្យប្រចាំឆ្នាំដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរបស់គ្រប់ក្រសួងស្ថាប័ន ជារបាយការណ៍ផ្លូវការបន្ទាប់មានការឯកភាពតាមរយៈកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ , គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (TWG) និងជាកម្មវត្ថុសម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលជាវេទិកាសម្រាប់វាយតម្លៃប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងបានឈានដល់ចំណុចរបត់ នោះគឺការបញ្ចប់ដំណាក់កាលទី២ និងត្រៀមចាប់ផ្តើមដំណាក់កាលទី៣ ជាឆ្នាំសម្រាប់បន្តពង្រឹងស្ថិរភាពនៃភាពជឿទុកចិត្តលើថវិកា និងការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដោយផ្តោតលើការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ដំណើការនៃកិច្ចប្រតិបត្តិការថ្មី ព្រមទាំងការសាកល្បងអង្គភាពថវិកា និងថវិកាកម្មវិធីពេញលេញ ដើម្បីត្រៀមលក្ខណៈសម្រាប់ការអនុវត្តជាចាំបាច់។ ដូចនេះផែនការដំណាក់កាលទី២ ថ្មី (CAP2-NEW) សម្រាប់ឆ្នាំ២០១៤-២០១៥ បានរៀបចំរួចរាល់នៅដើមខែមេសា ឆ្នាំ២០១៤ ដើម្បីត្រៀមលក្ខណៈសម្រាប់ការអនុវត្តក្នុងដំណាក់កាលអន្តរកាលនេះ និងបានផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នធ្វើជាមូលដ្ឋាន សម្រាប់រៀបចំផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន (GDAP2-New) និងរបស់ក្រសួង/ស្ថាប័ន (MAP2-New) ដែលមានសូចនាករប្រចាំត្រីមាសសម្រាប់វាស់វែងបានប្រសើរជាងមុន។

ទោះជាយ៉ាងណា ដើម្បីយើងអាចឱ្យតម្លៃរបាយការណ៍លទ្ធផលសម្រេចបាននៅឆ្នាំ២០១៤ បាន យើងគួររំលឹកឡើងវិញអំពីលទ្ធផល និងស្ថានភាពនៃការអនុវត្តផែនការសកម្មភាពនៅដំណាក់កាលទី២ នៅឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលបានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជារួម ពិនិត្យទៅលើ ១៤ គោលបំណង និង ៧៣ ចង្កោមសកម្មភាព និងចែកជា ៣ ផ្នែក ផ្នែកទី១ សម្រាប់បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា ផ្នែកទី២ សម្រាប់ការ បង្កើន គណនេយ្យភាពហិរញ្ញវត្ថុ និងផ្នែកទី៣ សម្រាប់ការត្រៀមលក្ខណៈជំហានបន្ទាប់ និងការបង្កើនការធ្វើសមាហរណកម្មថវិកា។ តាម រយៈរបាយការណ៍នេះ យើងពិនិត្យឃើញថាបានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពជារួម ដែលក្នុងនោះ ភាពជឿទុកចិត្តនៃថវិកាសម្រាប់ឆ្នាំ២០១៣ នៅតែរក្សាបានជាសារវន្ត ទោះជាជួបប្រទះបញ្ហា និងភាពរអាក់រអួលក្នុងការអនុវត្តនៅឆ្នាំកន្លងទៅ ក៏ដោយ។ ការត្រៀមលក្ខណៈសម្រាប់ដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ នៅក្នុង

ឆ្នាំ២០១៥ នេះ អាចអនុវត្តទៅបាន ទោះជាដំណាកើកាលទី២ មានភាពស្មុគស្មាញ និងជួបបញ្ហាប្រឈមច្រើនពិតមែន វិធានការដោះស្រាយសមស្រប និងទាន់ពេលត្រូវបានដាក់ចេញ។ ការចាប់ផ្ដើមដាក់ឱ្យអនុវត្តពេញលេញ និងអង្គភាពថវិកាសម្រាប់ក្រសួង ១០ អាចអនុវត្តបាន។

ជាមួយគ្នានេះ ការអនុវត្តនាឆ្នាំកន្លងទៅមិនប្រាកដថាបានប្រព្រឹត្តទៅដោយគ្មានបញ្ហា និងឧបសគ្គនោះទេ ជាក់ស្ដែងបញ្ហាប្រឈមមួយចំនួនត្រូវបានលើកឡើង ដើម្បីស្វែងរកវិធានការទប់ស្កាត់ និងដោះស្រាយឱ្យបានទាន់ពេល វេលា និងប្រកបដោយប្រសិទ្ធភាព ដែលបញ្ហាទាំងនោះបានផ្ដោតទៅលើបញ្ហាប្រឈមដែលមានចរិតជាការដឹកនាំ (គោលនយោបាយ គោលការណ៍ ឬការផ្ដល់ទិសដៅ), បញ្ហាប្រឈមដែលមានចរិតជាការគ្រប់គ្រង (ការកំណត់ សកម្មភាព ការចាត់ចែង ការគ្រប់គ្រង និងតាមដានអនុវត្ត), បញ្ហាប្រឈមដែលមានចរិតបច្ចេកទេស (ជំនាញ ច្បាស់លាស់ និងការបណ្ដុះបណ្ដាល) និងបញ្ហាប្រឈមដែលមានចរិតជារដ្ឋបាល និងសម្របសម្រួល (កិច្ចសហការ និងការផ្លាស់ប្ដូរព័ទ៌មាន)។ ដើម្បីជាវិធានការដោះស្រាយនូវរាល់បញ្ហាទាំងនេះ របាយការណ៍ក៏បានលើកឡើងជា អនុសាសន៍សម្រាប់បន្តកែលម្អក្នុងការអនុវត្តនៅឆ្នាំបន្ទាប់ ដែលកិច្ចការសំខាន់ៗមួយចំនួនពាក់ព័ន្ធទៅនឹងភាពជាម្ចាស់ និងការទទួលខុសត្រូវ និងគណនេយ្យភាពដែលគួរត្រូវបានពង្រឹងក្នុងឆ្នាំ២០១៣, គួរធ្វើការត្រួតពិនិត្យឡើងវិញ និងវាយ-តម្លៃជារួមលើប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាពនៃការបណ្ដុះបណ្ដាល, គួររៀបចំប្រព័ន្ធ និងយន្តការត្រួតពិនិត្យ និងវាយតម្លៃ លទ្ធផលការងារដោយផ្អែកលើសូចនាករវាស់វែងច្បាស់លាស់ សម្រាប់គ្រប់ក្រសួង/ស្ថាប័ន និងការបែងចែកឱ្យបាន ច្បាស់លាស់រវាងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ គឺជាមូលដ្ឋានងាយស្រួលសម្រាប់ការគ្រប់គ្រង។

សម្រាប់ឆ្នាំ២០១៤ នេះ ផែនការសកម្មភាពរួមដំណាក់កាលទី២ ត្រូវបានគាំទ្រដោយផ្នែកចំនួន៤ គឺ ផ្នែកទី១ **ភាពជឿទុកចិត្តបាននៃថវិការ** ,ផ្នែកទី២ **គណនេយ្យភាពហិរញ្ញវត្ថុ,** ផ្នែកទី៣ **ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់** និងផ្នែកទី៤ **ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព**។ កិច្ចការសំខាន់សម្រាប់ រយៈពេល២ឆ្នាំគឺតម្រូវឱ្យយើងបន្តផ្ដោតការយកចិត្តទុកដាក់លើភាពជឿទុកចិត្តបាននៃថវិកា ដើម្បីធានាឱ្យបាននូវ ភាពរលូន និងស្ថិរភាពនៃការអនុវត្តថវិកាក្នុងឆ្នាំ ព្រមទាំងការដាក់ឱ្យអនុវត្តជាស្ថាពរនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុជំហានទី១។ ជាលទ្ធផល ស្ថានភាពនៃភាពជឿទុកចិត្តបាននៃថវិកាត្រូវបានរក្សាជាសារវន្ត ដដែល ទោះបីជាបន្តនៅមិនទាន់មានស្ថិរភាពក្ដី សម្រាប់ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុកិច្ចការសំខាន់ៗ និងចាំបាច់ មួយចំនួនត្រូវបានអនុវត្ត ជាពិសេស សមាសធាតុចាំបាច់អាចយកមកប្រើប្រាស់បានសម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានទាន់ពេលវេលាក្នុងគោលកសាងប្រព័ន្ធគណនេយ្យភាព, ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ សកម្មភាពភាគច្រើនសម្រេចបានតាមគោលដៅ ដែលភាគច្រើននៃកិច្ចការនេះផ្ដោតលើ ការបន្តពង្រឹងភាពគ្រប់ជ្រង់ជ្រោយ និងសមាហរណកម្មថវិកា ជាពិសេសការពង្រឹងការការអនុវត្តផែនការយុទ្ធសាស្ត្រ ថវិកា និងការបន្តពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី, និងការងារសម្រាប់គាំទ្រទូទៅនិងកសាងសមត្ថភាព ដែលផ្ដោតលើយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស, ផែនការផ្សព្វផ្សាយ, ការបណ្ដុះបណ្ដាល ហាក់នៅពុំទាន់បានអនុវត្តទៅបានប្រសើរនៅឡើយទេ។

របាយការណ៍ស្តីពីវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០១៤នេះ នឹងរៀបរាប់ពីលទ្ធផលសម្រេចបានដោយលម្អិតទៅតាមផ្នែកនីមួយៗ រហូតដល់កម្រិតគោលបំណង និងចង្កោមសកម្មភាព ធៀបនឹងសូចនាករ ព្រមទាំងលើកឡើងពីបញ្ហាប្រឈមនិងអនុសាសន៍/ការងារត្រូវធ្វើបន្តផងដែរ។

ការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តសកម្មភាពរួមដំណាក់កាលទី ២ ថ្មីនេះ បានពិនិត្យទៅលើ÷

- ផ្នែកសំខាន់ៗ ៤ គឺ ភាពជឿទុកចិត្តនៃថវិកា គណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ និងការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព។
- ចំណែកឯ វិធីសាស្ត្រនៃការវាយតម្លៃវឌ្ឍនភាពដោយផ្អែកលើមូលដ្ឋាន ២ គឺ÷

  ១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត

  ២. លទ្ធផលសម្រេចបាន ធៀបនឹងសូចនាករគោលដៅ។

ដូចបានគូសបញ្ជាក់ខាងលើ របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំនេះ គឺជាឯកសារសំខាន់ចាំបាច់នឹងតម្រូវឱ្យមានការត្រួតពិនិត្យប្រកបដោយភាពគ្រប់ជ្រុងជ្រោយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។ ក្នុងការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ ថ្មីទាំងមូលសម្រាប់ឆ្នាំ២០១៤-២០១៥ ទន្ទឹមនឹងការបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាឆ្ពោះទៅរកប្រព័ន្ធរឹងមាំ និងប្រកបដោយស្ថិរភាពនោះ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុជាសារវន្តត្រូវតែសម្រេចឱ្យបាន រួមទាំងការត្រៀមលក្ខណៈជាបណ្តើរៗនៅក្នុងដំណាក់កាលទី២ នេះ ទើបអាចឈានទៅដំណាក់កាលទី៣ គឺ ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយធានានិរន្តរភាពនៃកម្មវិធីកែទម្រង់ទាំងមូល។

## II. លទ្ធផលសម្រេចបានតាមផ្នែក

សម្រាប់ឆ្នាំ២០១៤ នេះ នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី២ ថ្មីនេះ ដែលគាំទ្រដោយ៤ ផ្នែក រួមមានគោលបំណងចំនួន ១៦ និងចង្កោមសកម្មភាពចំនួន៦២។ សកម្មភាពការងារជាច្រើនត្រូវបានកំណត់ និងអនុវត្តដោយអង្គភាពចំនួន១២ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការចូលរួមពីក្រប់ក្រសួងស្ថាប័ន។ ជារួមឃើញថា ស្ថានភាពនៃផ្នែកទាំង៤ ទទួលបានលទ្ធផលជារួមដូចតទៅ÷ ផ្នែក**ភាពជឿទុកចិត្តបាននៃថវិកា** មាន៤ គោលបំណង និង ១៤ ចង្កោមសកម្មភាព សម្រេចបាន ៨៥%, ផ្នែក**បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** មាន៦ គោលបំណង និង ២៥ ចង្កោមសកម្មភាព សម្រេចបាន ៧៥%, ផ្នែក**ត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់** មាន ៤គោលបំណង និង ១៩ ចង្កោមសកម្មភាព សម្រេចបាន ៨២% និងការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព មាន ២ គោលបំណង និង ៤ ចង្កោមសកម្មភាព សម្រេចបាន ៧០%។

បើផ្អែកលើគោលបំណង និងចង្កោមសកម្មភាពនេះ សកម្មភាពដែលមានការខំប្រឹងប្រែង និងទទួលបានលទ្ធផលប្រសើរជាងគេ គឺការបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិការ អ្វីដែលជាក្តីបារម្ភនាពេលនេះ គឺសកម្មភាពដែលបម្រើឱ្យផ្នែក

បង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលលទ្ធផលបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងបន្ត និងបង្កើនសកម្មភាពបន្ថែមទៀត ជាពិសេសនៅពេលដែលប្រព័ន្ធបង្កើនគណនេយ្យភាពកំពុងត្រូវបានកសាង។ សម្រាប់ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ភាគច្រើនសកម្មភាពសម្រេចបានតាមគោលដៅ ហើយដែលជោគជ័យនៃកត្តានេះច្រើនស្ថិតនៅលើការពង្រឹងគោលការណ៍ណែនាំ និងការបណ្តុះបណ្តាល។ ចំពោះផ្នែកការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ពុំទាន់សម្រេចបានតាមគោលដៅនៅឡើយ ដែលសកម្មភាពភាគច្រើនពាក់ព័ន្ធនឹងការបណ្តុះឆន្ទៈកំណែទម្រង់ សមត្ថភាពដឹកនាំ និងគ្រប់គ្រង ព្រមទាំងយន្តការលើកទឹកចិត្ត។

## ១. ភាពជឿទុកចិត្តបាននៃថវិកា

ភាពជឿទុកចិត្តបាននៃថវិកាត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃប្រសិទ្ធភាពអនុវត្តថវិកា មានន័យថា គម្លាតចំណូល និងចំណាយថវិកាជាតិកាន់តែតូចធៀបនឹងច្បាប់ថវិកា ដែលបានអនុម័ត, លំហូរចំណូល និងចំណាយថវិកានេះក៏កាន់តែរលូន, ការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានស្ទើរតែទាំងស្រុងនូវបញ្ហាបំណុលកកស្ទះដែលមានពីមុនមក។

បើផ្អែកទៅលើលទ្ធផលដែលសម្រេចបានតាំងពីឆ្នាំ២០១៣ មក និងដោយផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះទាំង ៦ ឃើញថា គម្លាតចំណូល និងចំណាយថវិកាជាតិកាន់តែតូចធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត, លំហូរចំណូល និងចំណាយថវិកានេះបន្តកាន់តែរលូន, ការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានស្ទើរតែទាំងស្រុងនូវបញ្ហាបំណុលកកស្ទះនៅតែរក្សាបានជាសារវន្ត ប៉ុន្តែនៅមិនទាន់បានបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននោះទេ។ តាមរយៈរបាយការណ៍លទ្ធផលចង្កោមសកម្មភាពដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៨០% នៃគោលដៅចង្កោមសកម្មភាពដែលត្រូវអនុវត្ត ក៏បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តកែលម្អ និងការពង្រឹងការអនុវត្តផែនការលទ្ធកម្ម ក៏ដូចជាកម្មវិធីចំណាយប្រកបដោយស័ក្តិសិទ្ធភាពជាមួយនឹងការបន្តពង្រឹង និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រមូលចំណូល និងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីឆ្ពោះទៅធានាស្ថិរភាពនៃផ្នែកនេះ។

ទន្ទឹមគ្នានេះ បញ្ហាប្រឈមក៏តែងកើតមានជារឿយៗ តួយ៉ាងដូចជាប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការប្រមូលចំណូលតាមផែនការក្នុងឆ្នាំ និងការបង់ចំណូលចូលរតនាគារជាតិដោយរលូនប្រចាំខែនៅមានកម្រិត ហើយប្រសិទ្ធភាពនៃការអនុវត្តចំណាយផែនការក្នុងឆ្នាំ និងការទូទាត់ដោយរតនាគារជាតិ ដោយរលូនប្រចាំខែក៏នៅមានកម្រិតផងដែរ។ ជាមួយគ្នានេះ ថ្វីត្បិតតែសូចនាទាំង៦ ដែលបានបន្តតាមដាន ហើយបង្ហាញថា ភាពជឿទុកចិត្តបាននៃថវិកានៅរក្សាបានជាមូលដ្ឋានដែរនោះ ក៏ភាពជឿទុកចិត្តបាននៃថវិកានេះស្ថិតនៅភាពផុយស្រួយ ដោយសារប្រព័ន្ធពុំទាន់ជាក់លាក់ និងបានអនុវត្តពេញលេញនៅឡើយ។ ហេតុដូចនេះ របាយការណ៍ឆ្នាំ២០១៣ បានជំរុញឱ្យមានការងារចាំបាច់ត្រូវពង្រឹងបន្ថែមសំខាន់ៗដូចជា (១) បន្តពង្រឹងការគ្រប់គ្រង និងផែនការប្រមូលចំណូលឱ្យបានសមស្របក្នុងកម្រិតមួយមានស្ថិរភាពក្នុងឆ្នាំ (២) បន្តពង្រឹងការអនុវត្តថវិកា និងផែនការចំណាយឱ្យបានសមស្របដែលអាចជឿជាក់បាន និងអាចប៉ាន់ស្មានបាន (៣) បន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងគណនីធនាគារ ព្រមទាំងប្រសិទ្ធភាពនៃការប្រើប្រាស់

គណនីទោលរតនាគារជាតិ និងការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការទូទាត់ប្រកបដោយប្រសិទ្ធភាព (៤) បន្តពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងបំណុលទាំងបំណុលដែលត្រូវសង និងបំណុលដែលត្រូវទារ។

ដោយឡែក សម្រាប់ឆ្នាំ២០១៤ នេះ ភាពជឿទុកចិត្តបាននៃថវិកាត្រូវបានបន្តអនុវត្តដោយមានគោលបំណងចំនួន ៤ និង១៤ ចង្កោមសកម្មភាពដោយផ្តោតលើការបន្តពង្រឹងក្នុងគោលដៅឈានទៅរកស្ថិរភាពជាក់លាក់នៃភាពជឿទុកចិត្តបាននៃថវិកាតាមរយៈការពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល (២) ការពង្រឹងការគ្រប់គ្រងបំណុល (៣) កាពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារ (៤) ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ស្ថានភាព គម្លាតចំណូល និងចំណាយថវិកាជាតិនៅតែរក្សាបានកាន់តែតូចធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត, លំហូរចំណូល និងចំណាយថវិកានេះក៏កាន់តែរលូន, ការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានជាដ៏រាបទូវបញ្ហាបំណុលកកស្ទះ ក៏ប៉ុន្តែប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំពុំទាន់មានភាពសុក្រឹត និងសមត្ថភាពព្យាករណ៍ ហាក់នៅមានកម្រិត។ មានន័យថា សម្រាប់ឆ្នាំបន្ទាប់នេះនៅសល់កិច្ចការចាំបាច់ត្រូវការទាមទារឱ្យមានការពង្រឹងបន្ថែម ជាពិសេស ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តផែនការចំណូលនិងចំណាយក្នុងឆ្នាំ សមត្ថភាពព្យាករណ៍ក្នុងឆ្នាំ និងការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសាច់ប្រាក់ជាប្រព័ន្ធ និងជាយន្តការ។

ដើម្បីមើលពីស្ថានភាពនៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា របាយការណ៍នេះប្រើប្រាស់នូវមធ្យោបាយ២ សម្រាប់វាស់វែង និងតាមដានតាមរយៈការត្រួតពិនិត្យដោយផ្អែកលើលទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះ និងសកម្មភាពការងារដែលត្រូវបានកំណត់ និងអនុវត្តដោយអង្គភាពពាក់ព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្រសួងស្ថាប័នដទៃទៀតគិតជាភាគរយនៃការសម្រេចបានលើសកម្មភាពនីមួយៗ។

## ១.១. ផ្អែកលើលទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះ

ដោយពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង៦ ឆ្នាំ២០១៤ ឃើញថា មានសូចនាករ៤ អាចសម្រេចបានតាមគោលដៅដូចគ្នានៅក្នុងឆ្នាំ២០១៣ ដែរ ប៉ុន្តែតែសូចនាករខ្លះ ដែលសម្រេចបានតាមគោលដៅនៅឆ្នាំកន្លងទៅបែរជាពុំត្រូវបានរក្សាការសម្រេចបាននៅឆ្នាំ២០១៤ នេះទេ ហើយសូចនាករខ្លះទៀតពុំសម្រេចបាននៅឆ្នាំ២០១៣ ត្រូវបានកែលម្អ និងសម្រេចបាននៅឆ្នាំ២០១៤នេះ។

១. ដូចគ្នាទៅនឹងឆ្នាំ២០១៣ ដែរ ពុំមានបំណុលសាច់ប្រាក់កកស្ទះ ត្រូវបានសង្កេតឃើញនៅក្នុងឆ្នាំ២០១៤ នេះទេ ដែលគោលដៅកំណត់ គឺមិនឱ្យលើសពី២% នៃចំណាយសរុប។

២. ខុសគ្នាទៅនឹងឆ្នាំ២០១៣ ទោះបីជាលទ្ធផលតាមត្រីមាសនីមួយៗពុំបានបង្ហាញអំពីស្ថិរភាពនៃលទ្ធភាពបញ្ជាចំណាយទៅតាមកម្មវិធីចំណាយនៃផែនការសាច់ប្រាក់យ៉ាងណាក៏ដោយ ក៏លទ្ធផលចុងឆ្នាំ២០១៤ បង្ហាញអំពីការសម្រេចបាននូវលទ្ធភាពបញ្ជាចំណាយបាន៩៩,៦ % ដែលគោលដៅបានកំណត់មិនឱ្យតិចជាង៩៦% នៅឆ្នាំ២០១៤ កត្តានេះឆ្លុះបញ្ចាំងអំពីសូចនាករនេះសម្រេចបានតាមគោលដៅ។ លទ្ធផលនេះប្រសើរជាងឆ្នាំ២០១៣ ដែលលទ្ធភាពបញ្ជាចំណាយ

សម្រេចបានត្រឹម៩៤,៨ % ប៉ុណ្ណោះ ដែលបង្ហាញឱ្យឃើញអំពីលទ្ធភាពដែលអាណាប័កអាចអនុវត្តចំណាយក្នុងឆ្នាំកន្លងទៅពុំអនុវត្តបានតាមកម្មវិធី។

៣.ការអនុវត្តចំណាយតាមប្រភេទ: ចំណាយមូលធនអនុវត្តបាន៨៦,៧% (ឆ្នាំ២០១៣ បាន៨៥%) **ធៀបនឹងគោលដៅ ៨៥%,** ចំណាយសម្រាប់បៀវត្សអនុវត្តបាន ១០២,៦% (**ឆ្នាំ២០១៣ បាន ៩៩%**) **ធៀបនឹងគោលដៅ ៩៨%** , សេវា/ទំនិញអនុវត្តបាន ១១២,៧% (នៅឆ្នាំ២០១៣ បាន១០៤,៨%) **ធៀបនឹងគោលដៅ៩៥%**។ យោងតាមភាគរយតាមប្រភេទនីមួយៗ សូចនាករនេះសម្រេចបានតាមគោលដៅដូចគ្នាទៅនឹងឆ្នាំ២០១៣ ផងដែរ។

៤.កំណើនចំណូលមូលដ្ឋានពន្ធប្រចាំឆ្នាំ២០១៤ អនុវត្តបាន ១៦,៦១% នៃផ.ស.ស. ធៀបនឹងគោលដៅកំណើន ០,៥% នៃ ផ.ស.ស ប្រចាំឆ្នាំ (ឆ្នាំ២០១៣ សម្រេចបាន ១៥,១៦%នៃផ.ស.ស.)

ដោយឡែកសូចនាករ១ ទៀត មិនសម្រេចបានតាមគោលដៅ គឺ÷

១.ខុសគ្នាទៅនឹងឆ្នាំ២០១៣ នៅឆ្នាំ២០១៤ នេះ ចំណូលក្នុងស្រុកត្រូវអនុវត្តបានក្នុងរង្វង់ +/-៥%នៃច្បាប់ ជាក់ស្តែងលទ្ធផលសម្រេចបាន គឺ ១១០,៧% កើនឡើង ១០,៧% (នៅឆ្នាំ២០១៣ សម្រេចបាន ៩៦,៦%)។ ទោះជាយ៉ាងណាក៏ដោយ ក៏ការមិនសម្រេចបានតាមគោលដៅនេះមិនមានផលអវិជ្ជមានដល់សេដ្ឋកិច្ចជាតិទាំងមូលទេ ផ្ទុយទៅវិញនេះជាការបង្ហាញអំពីលទ្ធផលកំណើនចំណូលសរុបខ្ពស់ហួសពីការព្យាករណ៍ដោយសារតែលទ្ធផលផ្លែផ្កានៃការកែទម្រង់រដ្ឋបាលចំណូលរបស់អគ្គនាយកពាក់ព័ន្ធក្នុងរយៈកាលកន្លងទៅនេះ។ ជារួម សូចនាករនេះ ពុំសម្រេចបានតាមគោលដៅដូចឆ្នាំ២០១៣ ទេ។ ចំណែកឯសូចនាករមួយទៀត ពុំបានកំណត់គោលដៅច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងនោះ គឺការពង្រឹងការអនុវត្តគណនីទោលរតនាគារជាតិ។

| សូចនាករ | គោលដៅ | ឆ្នាំ ២០១៣ | ឆ្នាំ ២០១៤ |
|---|---|---|---|
| លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើរៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ | +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ | ១០៤,៥% | ១១០,៧%<br>(ដោយសារលទ្ធផលនៃកំណែទម្រង់រដ្ឋបាលគយ និងពន្ធដារ) |
| បំណុលកកស្ទះ | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២% នៃចំណាយសរុប | គ្មាន | គ្មាន |
| លទ្ធភាពបញ្ចាំចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់ | ត្រីមាសទី១: ១៥%<br>ត្រីមាសទី២: ៤៥%<br>ត្រីមាសទី៣: ៦៧%<br>ត្រីមាសទី៤: ៩៦% | ត្រីមាសទី១:១៣.៣%<br>ត្រីមាសទី២: ៣៧,៣%<br>ត្រីមាសទី៣: ៦០,៨%%<br>**ត្រីមាសទី៤: ៩៦,១%** | ត្រីមាសទី១: ១៥,៦%<br>ត្រីមាសទី២: ៣៣,២%<br>ត្រីមាសទី៣: ៥៦%<br>**ត្រីមាសទី៤: ៩៩,៦%** |
| ចំណាយតាមប្រភេទកាន់តែខិតទៅរកថវិកាដែលបានអនុម័ត | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>• បៀវត្ស: ៩៨%<br>• ទំនិញ/សេវា: ៩៥%<br>• មូលធន: ៨៥% | • បៀវត្ស: ១៣២,១%<br>• ទំនិញ/សេវា: ៧៩,៣%<br>• មូលធន: ៨៣,៤% | • បៀវត្ស: ១០២,៦%<br>• ទំនិញ/សេវា: ១១២,៧%<br>• មូលធន: ៨៦,៧% |
| ទិន្នផលចំណូលលើមូលដ្ឋានពន្ធ | បង្កើនឱ្យបាន ០.៥% នៃ ផសសក្នុងមួយឆ្នាំ | ១៥,១៦% | ១៦,៦១% |

*តារាង១÷ សូចនាការសមិទ្ធកម្មគន្លឹះ, ប្រភព÷តនាគារជាតិ*

ផ្អែកតាមលទ្ធផល សមិទ្ធកម្មគន្លឹះនេះ ឃើញថា ទោះបីជាសូចនាករទាំង ៤ខាងលើសម្រេចបានតាមគោលដៅយ៉ាងណាក៏ដោយ ក៏ការពុំបន្តរក្សាបានពីឆ្នាំមួយទៅឆ្នាំមួយទៀតចំពោះសូចនាករមួយចំនួនបង្ហាញអំពីការមិនទាន់មានស្ថិរភាពនៃភាពជឿទុកចិត្តបាននៃថវិកា ដែលជាទូទៅអាចរក្សាបានជាសារវន្តចាប់ឆ្នាំ២០០៨ មក។ ដើម្បីបន្តពិនិត្យមើលសកម្មភាពដែលបានដាក់ចេញក្នុងគោលដៅបន្តពង្រឹងផ្នែកនេះឱ្យបានកាន់តែប្រសើរថែមទៀត យើងនឹងពិនិត្យទៅលើគោលបំណងទាំង៤ ដែលចូលរួមគាំទ្រដោយចង្កោមសកម្មភាពជាច្រើន និងការសម្រេចបានជាលទ្ធផលគិតជាភាគរយធៀបនឹងគោលដៅដែលត្រូវអនុវត្ត។ សូមមើលឧបសម្ព័ន្ធ (ក) ដែលបញ្ជាក់លម្អិតអំពីសូចនាករនីមួយៗ ដែលជាមូលដ្ឋានសម្រាប់ការវាយតម្លៃអំពីស្ថានភាពខាងលើ។

## <u>១.២. លទ្ធផលនៃសកម្មភាពគន្លឹះសម្រាប់បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា</u>

ទន្ទឹមនឹងការវាយតម្លៃផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះដែលគិតជាបរិមាណដូចបានរៀបរាប់ខាងលើ និងដើម្បីធានាថា ប្រព័ន្ធយន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្សគ្រប់គ្រាន់ សម្រាប់បន្តបម្រើឱ្យភាពជឿទុកចិត្តបាននៃថវិកា យើងនឹងបន្តវាយតម្លៃការងារដែលអនុវត្តនៅកម្រិតចង្កោមសកម្មភាពជាគុណភាពបន្តទៀត។

ដោយផ្អែកលើចង្កោមសកម្មភាពដែលសម្រេចបាននៅឆ្នាំ២០១៣ ផ្នែកនេះសម្រេចបាន៨០% នៃគោលដៅចង្កោមសកម្មភាពដែលត្រូវអនុវត្ត។ សម្រាប់ឆ្នាំ២០១៤ សកម្មភាពទាំងនេះ ត្រូវបានបន្តអនុវត្តដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលមានចង្កោមសកម្មភាពចំនួន១៤ និងសម្រេចបានលទ្ធផល៨៥ % ក្នុងនោះ៥ សម្រេចបានតាមគោលដៅ ៧ កំពុងអនុវត្ត១ ទៀតមិនទាន់ដល់ពេលអនុវត្ត និង១ មានការយឺតយ៉ាវ គឺចង្កោមសកម្មភាព១១.៣ ការពង្រឹងសមត្ថភាពព្យាករណ៍ សមត្ថភាពគ្រប់គ្រង និងប្រសិទ្ធភាពនៃការអនុវត្តផែនការចំណូលពន្ធដារក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋានពន្ធដារ។ ទោះជាយ៉ាងណាក៏ដោយ ចង្កោមសកម្មភាពដែលយឺតនេះ ពុំមានទំហំធ្ងន់ធ្ងរដែលអាចប៉ះពាល់ដល់ការពង្រឹងភាពជឿទុកចិត្តបាននៃថវិកាទេ ប៉ុន្តែជាសកម្មភាពដែលយើងត្រូវបន្តសម្រេចឱ្យបាន ដើម្បីជាមូលដ្ឋានជាក់លាក់មួយក្នុងការធានាឱ្យផ្នែកនេះកាន់តែមានភាពជឿទុកចិត្តបានបន្ថែមទៀត។

### ១.២.១. ការពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល

គោលបំណងនេះត្រូវបានបន្តអនុវត្តពីផែនការសកម្មភាពរួមដំណាក់កាលទី ២ (CAP 2) នៅឆ្នាំ២០១៣ ដោយផ្តោតលើការបន្តកែលម្អរដ្ឋបាល និងគោលនយោបាយចំណូល ហើយត្រូវបានកែសម្រួលមកជាការពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល ដោយបានសម្រួចចង្កោមសកម្មភាពពី៦ មកត្រឹម៤ នៅឆ្នាំ២០១៤វិញ។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ ការងារកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ សម្រេចបានលទ្ធផលជាវិជ្ជមានផ្ទុយទៅវិញ កិច្ចការមួយចំនួនពាក់ព័ន្ធការកែសម្រួល និងការអនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម នៅមានការយឺតយ៉ាវ។ បញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តការងារនេះមានពាក់ព័ន្ធទៅនឹងការរៀបចំរចនាសម្ព័ន្ធថ្មី សមត្ថភាពមន្ត្រី និងកិច្ចសហការពីអង្គភាពពាក់ព័ន្ធ។ ជាវិធានការបន្តដែលបានដាក់ចេញនៅឆ្នាំ២០១៣ ការបន្តពង្រឹងផែនការប្រមូល

ចំណូលប្រចាំខែតាមច្បាប់ប្រចាំឆ្នាំ ការបង់ចូលរតនាគារជាតិដោយទៀងទាត់ ព្រមទាំងមិនអនុញ្ញាតឱ្យមានបំណុលពន្ធឆ្លងឆ្នាំ។

បើពិនិត្យមើលចង្កោមសកម្មភាពទាំង៤ ក្នុងឆ្នាំ២០១៤ នេះ ការងារសំខាន់ៗចំនួន៤ ត្រូវបានកំណត់សម្រាប់គាំទ្រដល់គោលបំណងទី១ រួមមាន ការព្យាករណ៍ផ្អែកលើម៉ូឌែលដ៏សុក្រឹត, យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមត្រូវបានអនុវត្ត, ចំណូលក្នុងស្រុកសរុបកើន០,៥ % នៃផសស និងការអនុវត្តចំណូលសម្រេចបាន +/- ៥% នៃច្បាប់។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្ត គោលបំណងនេះសម្រេចបាន៧០% ក្នុងនោះ ចង្កោមសកម្មភាព១១.១ សម្រេចបាន១០០%, ១១.២ សម្រេចបាន៦០%, និង ១១.៤ សម្រេចបាន៧៦%។ ដោយឡែក **ចង្កោមសកម្មភាព ដែលសម្រេចបានតិចជាង៥០% គឺ ១១.៣ ដែលពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពព្យាករណ៍សមត្ថភាពគ្រប់គ្រង និងប្រសិទ្ធភាពនៃការអនុវត្តផែនការចំណូលពន្ធដារ**។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗដែលសម្រេចបានជាវិជ្ជមានតាមគោលដៅរួមមាន៖ មានម៉ូដែលព្យាករណ៍ចំណូលដ៏សុក្រឹត្យ និងសេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។ ផ្ទុយទៅវិញ ការងារដែលត្រូវពង្រឹង និងពន្លឿន ដើម្បីសម្រេចឱ្យបានទាន់ពេលវេលាតាមផែនការដែលបានគ្រោងទុកគឺ (១) ការពង្រឹងការគ្រប់គ្រងរដ្ឋបាលគយតាមរយៈការបង្កើតបញ្ជរតែមួយជាតិ (Cambodian National Single Window), និងការពង្រីកប្រស័្វយប្រវត្តកម្មអាស៊ីគូដារ (ASACUDA) (២) ម៉ូដែលព្យាករណ៍ចំណូលពន្ធដារត្រូវបញ្ចប់ត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ, ការរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ, និងមជ្ឈមណ្ឌលទិន្នន័យ (Data Center) ត្រូវបានរៀបចំរួចរាល់ និងដាក់ឱ្យដំណើរការ (៣) ការរៀបចំនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ។ ចំពោះសេចក្តីព្រាងច្បាប់គ្រប់គ្រងការស៊ីណូ ទោះបីជាមិនទាន់ត្រូវបានអនុម័តនៅឡើយក្តី ក៏ការងារជាច្រើនត្រូវបានអនុវត្តតាមរយៈការរៀបចំកិច្ចប្រជុំជាច្រើនលើក ដើម្បីកែសម្រួលមុននឹងដាក់ពិភាក្សាជាសាធារណៈជាមួយប្រតិបត្តិករកាស៊ីណូដើម្បីប្រមូលធាតុចូលបន្ថែមទៀត។

ក្នុងការអនុវត្តដើម្បីសម្រេចបាននូវគោលបំណងនេះ ក៏មានបញ្ហាប្រឈមមួយចំនួនកើតឡើងផងដែរ គឺកង្វះជំនួយបច្ចេកទេស និងការមិនទាន់បែងចែកក្រុមការងារច្បាស់លាស់សម្រាប់ទទួលខុសត្រូវតាមមុខងាររបស់ខ្លួន។ ហើយដើម្បីកែលម្អគោលបំណងនេះឱ្យបានកាន់តែប្រសើរឡើងថែមទៀត អង្គភាពប្រមូលចំណូលគួរតែសហការជាមួយអគ្គនាយក-ដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីពន្លឿនការរៀបចំម៉ូដែលព្យាករណ៍ចំណូល និងត្រូវបែងចែកតួនាទីការទទួលខុសត្រូវរបស់មន្ត្រីឱ្យបានច្បាស់លាស់ ដោយរៀបចំលក្ខខណ្ឌយោងសម្រាប់មន្ត្រីម្នាក់ៗដែលទទួលបន្ទុក។

### ១.២.២. ការពង្រឹងការគ្រប់គ្រងបំណុល

ការពង្រឹងការគ្រប់គ្រងបំណុល គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងបន្តអនុវត្តនៅឆ្នាំ២០១៤ ដោយរក្សាចង្កោមសកម្មភាពដដែល។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ មានសកម្មភាពជាច្រើនសម្រេច

បានជាវិជ្ជមាន សម្រាប់គាំទ្រដល់ការប្រើប្រាស់ទិន្នន័យបំណុល ប៉ុន្តែការរៀបចំ និងអនុវត្តយុទ្ធសាស្រ្តគ្រប់គ្រងបំណុល ហាក់ដូចមិនទាន់មានភាពរលូននៅឡើយ។ ជាមួយគ្នានេះ បញ្ហាប្រឈមមួយចំនួនត្រូវបានសង្កេតឃើញថា មានកង្វះខាតធនធានមនុស្ស សមត្ថភាពមន្រ្តី និងការកែសម្រួលរចនាសម្ព័ន្ធ។ ជាវិធានការបន្ត ការបន្តពិនិត្យ និងកែសម្រួលសេចក្តីព្រាងប្រកាសស្តីពីយន្តការ វិធីសាស្រ្ត និងនីតិវិធីសម្រាប់ប្រតិបត្តិការគ្រប់គ្រងបំណុលសាធារណៈ ដែលរួមបញ្ចូលនូវសេចក្តីព្រាងស្តង់ដារនីតិវិធីប្រតិបត្តិការការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេស និងការតម្លើងប្រព័ន្ធ DMFAS ពី Version 5.3 ទៅ 6.0 គឺជាការងារចាំបាច់ដែលត្រូវពង្រឹងក្នុងជំហានបន្ទាប់។

បើពិនិត្យមើលចង្កោមសកម្មភាពទាំង៣ ក្នុងឆ្នាំ២០១៤ នេះ ការងារសំខាន់ៗចំនួន៣ ត្រូវបានកំណត់សម្រាប់គាំទ្រដល់គោលបំណងទី២ នេះ រួមមាន (១) ពិនិត្យមើលឡើងវិញ និងកែលម្អក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័នព្រមទាំងតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបំណុល (២) រៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្រ្តគ្រប់គ្រងថវិកាបំណុល និង (៣) បង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យបំណុល។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្តគោលបំណងនេះសម្រេចបាន៩២% ក្នុងនោះ ចង្កោមសកម្មភាព ១២.១ សម្រេចបាន ១០០%, ១២.២ សម្រេចបាន៨៦% និង ១២.៣ សម្រេបាន៩០%។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗដែលសម្រេចបានជាវិជ្ជមានតាមគោលដៅគឺ ក្របខណ្ឌគតិយុត្ត និងយន្តការគ្រប់គ្រងបំណុលត្រូវបានរៀបចំតាមរយៈលទ្ធផលសំខាន់ៗរួមមាន (១) សេចក្តីព្រាងប្រកាសចុងក្រោយស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការឲ្យប្រាក់គេខ្ចីត្រូវបានរៀបចំ និងសេចក្តីព្រាងបឋមប្រកាសស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់ប្រតិបត្តិការគ្រប់គ្រងបំណុលសាធារណៈ និងនីតិវិធីក្នុងការធានារបស់រដ្ឋត្រូវបានរៀបចំ (២) របាយ-ការណ៍បច្ចុប្បន្នកម្មវិភាគចីរភាពបំណុលត្រូវបានពិនិត្យ និងកែសម្រួល និងរបាយការណ៍វិភាគចង្កោម បំណុលត្រូវបានរៀបចំ (៣) ប្រព័ន្ធគ្រប់គ្រងបំណុល DMFAS 6.0 ត្រូវបានតម្លើងរួចរាល់ និងបានបណ្តុះបណ្តាលមូលដ្ឋានគ្រឹះក្នុងការប្រើប្រាស់មុនផែនការអនុវត្តក្នុងត្រីមាសទី៤ និងសេចក្តីព្រាងព្រឹត្តិប័ត្របំណុលត្រូវបានរៀបចំ។ ផ្ទុយទៅវិញ ការងារដែលត្រូវពង្រឹង និងពន្លឿន ដើម្បីសម្រេចឱ្យបានទាន់ពេលវេលាតាមផែនការដែលបានគ្រោងទុកគឺ "សេចក្តីព្រាងចុងក្រោយស្តីពីបច្ចុប្បន្នកម្មយុទ្ធសាស្រ្តគ្រប់គ្រងបំណុលសាធារណៈ ២០១៤-២០១៨ ត្រូវបានអនុម័ត" និង "ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ននិងធនធានមនុស្សត្រូវបានធ្វើបច្ចុប្បន្នភាព និងត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្ត"។ មូលហេតុដែលមិនសម្រេចបានតាមគោលដៅនេះ ដោយហេតុថា យុទ្ធសាស្រ្តគ្រប់គ្រងបំណុលសាធារណៈ ២០១៤-២០១៨ ត្រូវបន្ថែមឧបសម្ព័ន្ធមួយទៀត គឺគោលនយោបាយគ្រប់គ្រងហានិភ័យបំណុលសាធារណៈ។

ទន្ទឹមនេះ បញ្ហាប្រឈមក៏ត្រូវបានសង្កេតឃើញនៅក្នុងគោលបំណងនេះផងដែរ តាមរយៈកត្តាមួយចំនួនដូចជាការអនុវត្តដើម្បីសម្រេចបានតាមសូចនាករដែលបានកំណត់ពុំត្រូវបានយកចិត្តទុកដាក់ និងត្រួតពិនិត្យតាមដាន និងការងារមួយចំនួនទៀតត្រូវសម្រេចបានតាមការកំណត់ ប៉ុន្តែដោយការបន្ថែមសកម្មភាពមួយចំនួនទៀតធ្វើឱ្យសកម្មភាពនោះយឺតយ៉ាវទៅវិញ។ ហើយដើម្បីកែលម្អគោលបំណងនេះឱ្យបានកាន់តែប្រសើរឡើងថែមទៀត សកម្មភាពគន្លឹះត្រូវបន្តអនុវត្តដូចជា (១) បញ្ចប់ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុល

សាធារណៈ ដើម្បីដាក់ឱ្យថ្នាក់ដឹកនាំអនុម័តនិងដាក់ឲ្យអនុវត្ត (២) បញ្ចប់សេចក្តីព្រាងបច្ចុប្បកម្មយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១៤-២០១៨ ដើម្បីដាក់ឱ្យថ្នាក់ដឹកនាំអនុម័ត និងដាក់ឲ្យអនុវត្ត និង (៣) បង្កើនសុក្រឹតភាពនៃការរៀបចំរបាយការណ៍វិភាគចីរភាពបំណុលដោយដោះស្រាយបញ្ហាប្រឈម និងកង្វះខាតទិន្នន័យមួយចំនួនសម្រាប់ធ្វើការវិភាគចីរភាពបំណុល។

### ១.២.៣. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារ

ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារ គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងបន្តអនុវត្តនៅឆ្នាំ២០១៤ ដោយរក្សាចង្កោមសកម្មភាពដដែល។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ មានសកម្មភាពជាច្រើនសម្រេចបានជាវិជ្ជមាន សម្រាប់គាំទ្រដល់គោលបំណងនេះ តួយ៉ាងសកម្មភាពសម្រាប់បន្តពង្រីកវិសាលភាព ការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល-ចំណាយថវិកា និងការតាមដានអាណត្តិមិន ទាន់ទូទាត់ និងអាយុកាលរបស់វា ព្រមទាំងទឹកប្រាក់ត្រូវសងត្រូវបានពង្រឹងយ៉ាងមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ សកម្ម-ភាពសម្រាប់បម្រើគោលដៅក្នុងការប្រមូលផ្តុំគណនីធនាគាររដ្ឋាភិបាល និងពង្រឹងគណនីទោលរតនាគារ (TSA) នៅមិនទាន់សម្រេចបានចប់សព្វគ្រប់។ ជាមួយគ្នានេះ បញ្ហាប្រឈមមួយចំនួនត្រូវបានសង្កេតឃើញថា ក្រៅពីកង្វះសម្ភារៈ និងថវិកាការងារមួយចំនួននៅមិនទាន់អនុវត្តតាមផែនការដូចជាការសិក្សា និងពិនិត្យឡើងវិញនូវការលទ្ធភាពប្រមូលផ្តុំគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងរចនាសម្ព័ន្ធគណនីទោល ដោយសារការប្រមូលផ្តុំគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងរចនាសម្ព័ន្ធគណនីទោល គឺជាបញ្ហាប្រឈមដែលមានលក្ខណៈស្មុគស្មាញ ដោយមិនមានមូលដ្ឋាន និងប្រភពច្បាស់លាស់ក្នុងការពិនិត្យតាមដានផ្សេងវិញទៀត ផែនការជាជំហានៗសម្រាប់អនុវត្តគណនីបង្គរ ត្រូវការប្រើរយៈពេលយូរលើសពី៥ ឆ្នាំ។ ជាវិធានការបន្ត ការងារចាំបាច់មួយចំនួនត្រូវបានកំណត់ដូចជា ការប្រមូលផ្តុំ និងពង្រឹងបន្ថែមការធ្វើផែនការសាច់ប្រាក់, កសាងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដោយមានគោលការណ៍ និងនីតិវិធីសម្រាប់អង្គភាពពាក់ព័ន្ធ ដើម្បីបង្កើតការព្យាករណ៍លំហូរសាច់ប្រាក់ និងការព្យាករណ៍សមតុល្យប្រាក់ចុងថ្ងៃ នៅគណនីទោលរតនាគារឱ្យមានភាពត្រឹមត្រូវ និងទាន់ពេលវេលា។

បើពិនិត្យមើលចង្កោមសកម្មភាពទាំង៤ ក្នុងឆ្នាំ២០១៤ ការងារសំខាន់ៗត្រូវបានផ្តោតទៅលើការពង្រឹងគណនីទោល និងប្រព័ន្ធធនាគារពេញលេញ ព្រមទាំងការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្តគោលបំណងនេះសម្រេចបាន៩៦% ក្នុងនោះចង្កោមសកម្មភាព១៣.១ និង ១៣.៤ សម្រេចបាន១០០%, ចង្កោមសកម្មភាព១៣.២ សម្រេចបាន៩៦%, ១៣.៣ សម្រេចបាន៨៧%។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗដែលសម្រេចបានជាវិជ្ជមានតាមគោលដៅគឺ (១) ពង្រឹងឱ្យកាន់តែមានស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងគណនី និងការគ្រប់គ្រងសាច់ប្រាក់តាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារពេញលេញ ដោយគណនីទោលរតនាគារនៅរាជធានី ខេត្តត្រូវបានតាមដាន និងកំណត់ច្បាស់លាស់ និងប្រមូលចងក្រងគណនីគម្រោងរបស់ដៃគូអភិវឌ្ឍ (២) ការកត់ត្រា និងតាមដានទិន្នន័យអាណត្តិបើកប្រាក់មានភាពសុក្រឹតច្បាស់លាស់។ ផ្ទុយទៅវិញ ការងារដែលត្រូវពង្រឹង និងពន្លឿន ដើម្បីសម្រេចឱ្យបានទាន់ពេលវេលាតាមផែនការដែលបានគ្រោងទុក គឺ (១) ប្រតិបត្តិការចំណូល និងចំណាយសាធារណៈត្រូវបានប្រើប្រាស់តាមប្រព័ន្ធធនាគារ១០០% ហើយនឹង

ឈានទៅប្រើប្រាស់ប្រព័ន្ធ E-Transfe។ ការមិនសម្រេចបានតាមគោលដៅនេះដោយសារការប្រើប្រាស់ប្រព័ន្ធ E-Transfer អាចមានហានិភ័យ ព្រោះមិនមានឯកសារ Hard Copy សម្រាប់ត្រួតពិនិត្យនិងតម្កល់ទុក។ ជាដំណោះស្រាយ អគ្គនាយកដ្ឋានរតនាគារត្រូវការពេលវេលាក្នុងសិក្សាលម្អិតពីគុណសម្បត្តិ និងគុណវិបត្តិរបស់ប្រព័ន្ធ E-Transfer ជាមួយធនាគារជាតិនៃកម្ពុជា (២) សាកល្បងរៀបចំផែនការសាច់ប្រាក់ប្រចាំថ្ងៃនិងសប្តាហ៍ និងការពិនិត្យតាមដានការគ្រប់គ្រងសាច់ប្រាក់។ ការមិនសម្រេចបានតាមគោលដៅនេះ ដោយសារការព្យាករណ៍នៅពុំទាន់ខិតជិតនឹងចំណូល-ចំណាយជាក់ស្តែងនៅឡើយ។ ទោះបីជាបានរៀបចំបណ្តុះបណ្តាលគ្រប់ក្រសួង ស្ថាប័ន ពីការធ្វើផែនការសាច់ប្រាក់របស់ខ្លួនក៏ដោយ ក៏អង្គភាពពាក់ព័ន្ធពុំទាន់បានផ្តល់ព័ត៌មាន និងរបាយការណ៍តាមការស្នើសុំ គួបផ្សំជាមួយអគ្គនាយកដ្ឋានរតនាគារជាតិពុំមិនទាន់មានប្រព័ន្ធ Software Online សម្រាប់ឱ្យក្រសួង ស្ថាប័នថ្នាក់កណ្តាលទាំងអស់បញ្ចូលទិន្នន័យផែនការចំណូល-ចំណាយរបស់ខ្លួនដើម្បីឱ្យការធ្វើផែនការមានភាពត្រឹមត្រូវ និងបានទាន់ពេលវេលា។

ហើយដើម្បីកែលម្អគោលបំណងនេះឱ្យបានកាន់តែប្រសើរឡើងថែមទៀត សកម្មភាពគន្លឹះត្រូវបន្តអនុវត្តក្នុងឆ្នាំ ២០១៥ ខាងមុខ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបន្តជំរុញក្នុងការអភិវឌ្ឍប្រព័ន្ធ Software Online រួមទាំងបង្កើតយន្តការត្រួតពិនិត្យជាប្រចាំ និងបណ្តុះបណ្តាលដល់ក្រសួង ស្ថាប័នថ្នាក់កណ្តាលឱ្យធ្វើបច្ចុប្បន្នទិន្នន័យ។

ជារួម តាមរយៈការរៀបចំរួចរាល់នូវក្របខណ្ឌគតិយុត្ត និងយន្តការនៃការអនុវត្តគណនីទោលពេញលេញ និងក្របខណ្ឌគតិយុត្ត យន្តការ និងនិតិវិធីនៃការអនុវត្តប្រព័ន្ធធនាគារពេញលេញ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារត្រូវបានពង្រឹងបន្ថែម ប៉ុន្តែនៅពុំទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ ដែលចាំបាច់ត្រូវការនូវការរៀបចំក្របខ័ណ្ឌ គតិយុត្ត យន្តការ និងនីតិវិធីនៃការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយតម្លាភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

### ១.២.៤.ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ

ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងបន្តអនុវត្តនៅឆ្នាំ២០១៤ ដោយបានសម្រួលចង្កោមសកម្មភាពពី៦ មកត្រឹម៣ ។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ សកម្មភាពជាច្រើនពុំទាន់អនុវត្តបានតាមផែនការនៅឡើយទេ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់នោះ គឺការបង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្ម តាមរយៈការផ្សព្វផ្សាយជាសាធារណៈ និងដោយចំហ សម្រេចបានពេញលេញ។ ផ្ទុយទៅវិញ ការអនុវត្តអនុក្រឹត្យថ្មីស្តីពីលទ្ធកម្មសាធារណៈ និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ ព្រមទាំងការកំណត់ឱ្យបានច្បាស់លាស់ពីបន្ទាត់គណនេយ្យភាពក្នុងដំណើរការលទ្ធកម្មហាក់មានការយឺតយ៉ាវនៅឡើយ។ បញ្ហាប្រឈមដែលសង្កេតឃើញកន្លងមកនេះ គឺពាក់ព័ន្ធទៅនឹងការសម្របសម្រួលពីអគ្គនាយកដ្ឋានទៅអគ្គនាយកដ្ឋានមួយ, កង្វះសមត្ថភាពមន្ត្រី និងកង្វះការតាមដាន និងត្រួតពិនិត្យលើសកម្មភាពដែលបានដាក់ចេញ ជាពិសេស លិខិតបទដ្ឋានគតិយុត្តមួយចំនួន សម្រាប់អនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនទាន់បានអនុម័ត។ ជាវិធានការបន្ទាប់ សកម្មភាពមួយចំនួនត្រូវបានកំណត់ គឺការជំរុញការអនុម័តនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋាននានាស្តីពីលទ្ធកម្មសាធារណៈ។

បើពិនិត្យមើលចង្កោមសកម្មភាពទាំង៣ ក្នុងឆ្នាំ២០១៤ ការងារសំខាន់ៗត្រូវបានផ្តោតទៅលើការយន្តការ និងអនុវត្តថវិកា និងផែនការចំណាយដែលនឹងត្រូវបានសម្រួល និងពង្រឹង។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្តគោល

បំណងនេះសម្រេចបាន៨៩% ក្នុងនោះ ១៤.៣ សម្រេចបាន១០០% និងចង្កោមសកម្មភាព ១៤.២ សម្រេចបាន ៨៣% ។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗដែលសម្រេចបានជាវិជ្ជមានតាមគោលដៅ គឺបែបបទនៃការទូទាត់សម្រាប់គម្រោងវិនិយោគ និងកម្មវិធីថែទាំហេដ្ឋានរចនាសម្ព័ន្ធសាធារណៈត្រូវបានអនុម័ត និងអនុវត្តការទូទាត់ចំណាយតាមផែនការចំណាយ។ ផ្ទុយទៅវិញ ការងារដែលត្រូវពង្រឹង និងពន្លឿន ដើម្បីសម្រេចឱ្យបានទាន់ពេលវេលាតាមផែនការដែលបានគ្រោងទុក គឺ (១) ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា និងវិវាទលទ្ធកម្ម, ការរៀបចំធ្វើបច្ចុប្បន្នភាពសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ (IRRPP) ដោយធ្វើសុខដុមនីយកម្មជាមួយស្តង់ដារនីតិវិធីរួម, បង្កើតប្រព័ន្ធគ្រប់គ្រងលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (២) ការកែលម្អនីតិវិធីនៃការរៀបចំ និងផ្តល់ការធានាចំណាយថ្មី និងលឿន។ អង្គភាពពាក់ព័ន្ធត្រូវបង្កើនការយកចិត្តទុកដាក់ តាមដាន និងជំរុញការអនុវត្តឱ្យបានតាមគោលដៅកំណត់។

ទន្ទឹមនេះ បញ្ហាប្រឈមក៏ត្រូវបានសង្កេតឃើញនៅក្នុងគោលបំណងនេះផងដែរ តាមរយៈកត្តាមួយចំនួនដូចជា (១) ការរៀបចំសកម្មភាព និងការកំណត់សូចនាករមិនទាន់មានភាពសុក្រឹត និងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាព និងគោលបំណងដែលបានកំណត់ (២) កង្វះការគាំទ្រពីត្រួតពិនិត្យផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានក្នុងការជំរុញការងារឱ្យទាន់ផែនការ និងស្របទៅតាមសូចនាករដែលបានកំណត់ (៣) កង្វះប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្មការងារផ្ទៃក្នុងរបស់អគ្គនាយកដ្ឋាន។

ជាវិធានការបន្ទាប់ សកម្មភាពមួយចំនួនត្រូវបានលើកឡើងដោយបានស្នើសុំឱ្យអគ្គនាយកដ្ឋានពាក់ព័ន្ធគួរពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងសូចនាករតាមត្រីមាសឱ្យមានសុក្រឹតភាព និងសង្គតិភាពទៅតាម CAP 2 New និងគួររៀបចំកិច្ចប្រជុំប្រចាំខែឱ្យបានទៀងទាត់ ដើម្បីត្រួតពិនិត្យសមិទ្ធកម្មការងារ។

ជារួម ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ មិនទាន់សម្រេចតាមគោលដៅកំណត់ពេញ-លេញនៅឡើយទេ ដោយហេតុថា អគ្គនាយកដ្ឋានពាក់ព័ន្ធគួរពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងសូចនាករតាមត្រីមាសឱ្យមានសុក្រឹត្យភាព និងសង្គតិភាពទៅតាមសកម្មភាពរួមដំណាក់កាលទី២ ថ្មី (២)រៀបចំកិច្ចប្រជុំប្រចាំខែឱ្យបានទៀងទាត់ ដើម្បីត្រួតពិនិត្យសមិទ្ធកម្មការងារ។

ដូចនេះ គោលបំណងទាំង៤ ដូចបានរៀបរាប់ខាងលើនេះ ជាការពន្យល់បន្ថែមអំពីការសម្រេចបាននូវសូចនាករសំខាន់ៗមួយចំនួនក៏ដូចជាការទាមទារឱ្យមានការពង្រឹងនូវកិច្ចការមួយចំនួនទៀតដែលពុំទាន់សម្រេចបាន។ ជាវិធានការបន្ត និងក្នុងគោលដៅរក្សាស្ថិរភាពនៃភាពជឿទុកចិត្តបាននៃថវិកា ទិសដៅជាក់លាក់មួយចំនួនគួរត្រូវបានកំណត់នៅក្នុង CAP 3 ពោលគឺ ការអនុវត្តចំណូលនិងចំណាយប្រចាំត្រីមាសមានភាពរលូន និងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនឱ្យលើស៥% ធៀបនឹងការអនុវត្តចំណូល-ចំណាយ) និងការគ្រប់គ្រងបំណុល (ត្រូវសង និងត្រូវទារ) ក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព។ ថ្វីត្បិតតែពុំមានបំណុលកកស្ទះ (ក្របខណ្ឌ៩០ ថ្ងៃ) ប៉ុន្តែការឈានទៅរកស្ថិរភាព និងការសម្រេចបាននូវប្រព័ន្ធដ៏រឹងមាំនៃភាពជឿទុកចិត្តបាននៃថវិកា លុះត្រាមានយន្តការកត់ត្រា និងប្រព័ន្ធរបាយការណ៍

ច្បាស់លាស់ និងទាន់ពេលវេលាលើបំណុលកកស្ទះ (ទាំងបំណុលដែលត្រូវទា និងបំណុលដែលត្រូវសង) ជាពិសេសទៅទៀតមានតែការឈានទៅបង្កើនស្តង់ដាររហូតដល់ទៅ ៦០ ថ្ងៃ និង/ ឬ៣០ ថ្ងៃ ទើបអាចធានាបាន។

គោលដៅការងារដូចបានរៀបរាប់ខាងលើ នឹងត្រូវសម្រេចឱ្យបាននៅឆ្នាំ ២០១៤ និង ២០១៥ ដើម្បីជាការពង្រឹងជំហរជាក់លាក់ក្នុងការឈានទៅដំណាក់កាលទី៣ បាននៅឆ្នាំ ២០១៦ ក្នុងពេលដែលគណនេយ្យភាពហិរញ្ញវត្ថុ ជាសារវន្តនឹងត្រូវសម្រេចបាននៅក្នុងពេលបញ្ចប់ CAP 2 New នេះ។ជាវិធានការបន្ត និងក្នុងគោលដៅរក្សាស្ថិរភាពនៃភាពជឿទុកចិត្តបាននៃថវិកា ទិសដៅជាក់លាក់មួយចំនួនកំពុងត្រូវបានកំណត់នៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៣ ពោលគឺ ការអនុវត្តចំណូលនិងចំណាយប្រចាំត្រីមាសមានភាពរលូន និងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនឱ្យលើស៥% ធៀបនឹងការអនុវត្តចំណូល-ចំណាយ) និងការគ្រប់គ្រងបំណុល (ត្រូវសង និងត្រូវទារ) ក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព។

## ២:គណនេយ្យភាពហិរញ្ញវត្ថុ

ដូចដែលបានគូសបញ្ជាក់ពីខាងដើមរួចមកហើយ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុជាសារវន្តត្រូវតែសម្រេចឱ្យបានទើបអាចឈានទៅដំណាក់កាលទី៣ ទន្ទឹមនឹងការបង្កពង្រឹងភាពជឿទុកចិត្តបាននៃថវិកាឆ្ពោះទៅរកប្រព័ន្ធដ៏រឹងមាំ និងប្រកបដោយស្ថិរភាព។ តើការសម្រេចជាសារវន្តនេះ ត្រូវចូលរួមគាំទ្រដោយសកម្មភាពបែបណានោះ យើងនឹងត្រូវពិនិត្យលទ្ធផលដែលរំលេចឡើងនៅក្នុងផ្នែកនេះតាមគោលបំណង និងចង្កោមសកម្មភាពដែលបានដាក់ចេញ។

គណនេយ្យភាពហិរញ្ញវត្ថុ គឺជាគោលដៅចម្បងនៃដំណាក់កាលទី២ នេះ ដែលផ្តោតសំខាន់ទៅលើ (១) ការកែលម្អលើការអនុវត្តថវិកា (២) ការកែលម្អលើប្រព័ន្ធគណនេយ្យ ការកត់ត្រា ការធ្វើរបាយការណ៍ (៣) ការបង្កើនភាពគ្រប់ជ្រុងជ្រោយ គណនេយ្យភាព និងតម្លាភាព។ ថ្វីត្បិតតែសកម្មភាពការងារជាច្រើនត្រូវបានអនុវត្តក្នុងរយៈកាលកន្លងទៅ ដែលផ្តោតលើការរៀបចំកិច្ចដំណើរការប្រតិបត្តិការថ្មី ការរៀបចំមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំដាក់ឱ្យអនុវត្តអង្គភាពថវិកាជាដើម ក៏ប៉ុន្តែលទ្ធផលនៃគណនេយ្យភាពហិរញ្ញវត្ថុមិនទាន់ទទួលបានជាប្រព័ន្ធនៅឡើយទេ ដោយសារតែចំណែកនីមួយៗនៃប្រព័ន្ធពុំទាន់បានផ្គុំចូលគ្នាគ្រប់ជ្រង់ជ្រោយ និងពេញលេញនៅឡើយ។ បើផ្អែកទៅលើលទ្ធផលដែលសម្រេចបានតាំងពីឆ្នាំ២០១៣មក ឃើញថា មានសកម្មភាពជាច្រើនបានបម្រើឱ្យផ្នែកនេះ និងសម្រេចបានប្រមាណ៧០% នៃគោលដៅចង្កោមសកម្មភាពដែលត្រូវអនុវត្ត។ ជារួម បើផ្អែកលើចង្កោមសកម្មភាពដែលសម្រេចបាន ឃើញថា ទោះបីជាផ្នែកនេះពុំទាន់អាចកំណត់សូចនាករ និងគោលដៅច្បាស់លាស់ដែលអាចវាស់វែងលទ្ធផលបានជាបរិមាណ និងគុណភាពក៏ពិតមែនក្តី ប៉ុន្តែជាតម្រូវការចាំបាច់សម្រាប់ការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាតាមគោលដៅអាចធានាបាន។ ទោះជាយ៉ាងណា គម្រោងប្រព័ន្ធព័ត៌មានវិទ្យានេះត្រូវតែចាប់ផ្តើមពិចារណាអំពីអ្វីដែលត្រូវធ្វើក្រោយពីបានដាក់ឱ្យអនុវត្តជំហានទី១ នៅចុងឆ្នាំ២០១៥ រួចមក រួមទាំងផែនការសម្រាប់ពង្រីកប្រព័ន្ធព័ត៌មានវិទ្យានេះនៅជំហានទី២ បន្ទាប់ទៀត ហើយដែលត្រូវការត្រៀមលក្ខណៈគ្រប់គ្រាន់នៅក្នុងជំហានជាបន្តបន្ទាប់ទៀត។ ទន្ទឹមគ្នានេះដែរ បញ្ហាប្រឈមមួយចំនួនត្រូវបានពិនិត្យឃើញនៅក្នុងការអនុវត្តកន្លង

ទៅនេះពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់នៃការគាំទ្រហិរញ្ញប្បទាននៃការកែទម្រង់ដែលគាំទ្រដល់គម្រោងព័ត៌មានវិទ្យា និងសេចក្តីត្រូវការបណ្តុះបណ្តាលបន្ថែម និងបន្ទាន់ជាពិសេសពាក់ព័ន្ធ នឹងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា ក៏ដូចជាការប្រើប្រាស់ប្រព័ន្ធនេះ សម្រាប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។

ដោយឡែកសម្រាប់ឆ្នាំ២០១៤ សម្រាប់ឆ្នាំ២០១៤ នេះ គណនេយ្យភាពហិរញ្ញវត្ថុត្រូវបានបន្តអនុវត្តដោយមានគោលបំណងចំនួន៦ និងចង្កោមសកម្មភាពចំនួន២៦ ដោយផ្តោតទៅលើ (១) ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី (២) ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី (៣) ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព (៤) ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព (៥) ពង្រឹង និងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា (៦) ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។

ស្ថានភាពនៃគណនេយ្យភាពហិរញ្ញវត្ថុនៅចុងឆ្នាំ២០១៤ ជារួម សម្រេចបាន៧៥% ជាការសន្និដ្ឋានកិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួន ជាពិសេស សមាសធាតុចាំបាច់អាចយកមកប្រើប្រាស់បានសម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានទាន់ពេលវេលាតាមក្នុងការដាក់ឱ្យអនុវត្តនៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៥ ខាងមុខនេះ។ ការជាព្រួយបារម្ភ ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការនិងការបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព ជាពិសេស ចំពោះក្រសួង ស្ថាប័ន ១០ ដែលអនុវត្តថវិកាកម្មវិធីពេញលេញ ពុំទាន់ត្រូវបានរៀបចំជាសកម្មភាពឱ្យបានជាក់លាក់នៅឡើយទេ។

ដើម្បីដឹងពីស្ថានភាពនៃគណនេយ្យភាពហិរញ្ញវត្ថុថា សម្រេចបានក្នុងកម្រិតបែបណានោះ របាយការណ៍នេះនឹងបង្ហាញជូនអំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរទៅតាមគោលបំណងនីមួយៗជាបន្តបន្ទាប់។

## <u>២.១. ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី</u>

ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងបន្តអនុវត្តនៅឆ្នាំ២០១៤ ដោយបានសម្រួលចង្កោមសកម្មភាពពី៦ មកត្រឹម៤ ដោយផ្តោទៅលើប្លង់គណនេយ្យថ្មីត្រូវដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០១៥, ដាក់ឱ្យអនុវត្តពេញលេញចំណាត់ថ្នាក់ថវិកាថ្មី យ៉ាងតិច ៤ ចំណាត់ថ្នាក់ គឺ ចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច និងសិក្សាត្រៀមដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ ៣ បន្ថែមទៀតគឺ មុខងារ មូលនិធិ និងគម្រោង។ ដោយឡែក ទោះបីជាសកម្មភាពជាច្រើនពុំទាន់អនុវត្តបានតាមផែនការនៅឡើយទេ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់នោះ សកម្មភាពសម្រាប់បង្កើនជម្រើសសម្រាប់អនុវត្តចំណាត់ថ្នាក់តាមកម្មវិធី និងតាមមុខងារ និងលទ្ធផលអាទិភាពផ្សេងទៀតត្រូវបានអនុវត្តចប់ជាស្ថាពរ។ ផ្ទុយទៅវិញសកម្មភាពសម្រាប់បង្កើតផែនការជាជំហានៗ សម្រាប់ឈានទៅអនុវត្តគណនីបង្គរ អនុវត្តទៅនៅមានការយឺតយ៉ាវនៅឡើយ។ ជាវិធានការបន្តការរៀបចំព្រាងមាតិកាថវិកាលម្អិតដើម្បីដាក់ឱ្យអនុវត្តផ្នែកខ្លះនៃចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់មូលនិធិ ចំណាត់ថ្នាក់មុខងារ និងការរៀបចំតារាងសម្រាប់ធ្វើថវិកាតាមមាតិកាដូចជាការរៀបចំសារាចរ ប្រកាសដាក់ឱ្យអនុវត្តថវិកាថ្មីជាកិច្ចការដែលត្រូវពង្រឹង។

បើពិនិត្យមើលចង្កោមសកម្មភាពនៅក្នុងឆ្នាំ២០១៤ វិញ ឃើញថាកិច្ចការសំខាន់ៗចំនួន ៤ នឹងត្រូវបន្តអនុវត្តនោះ គឺ (១) ត្រួតពិនិត្យឡើងវិញនិងបន្តកែលម្អប្លង់គណនេយ្យថ្មី (២) ត្រួតពិនិត្យឡើងវិញនិងបន្តកែលម្អចំណាត់ថ្នាក់ថវិកាថ្មី ដើម្បីដាក់អនុវត្តឱ្យពេញលេញយ៉ាងតិច ៤ គឺចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច និង (៣) សិក្សានិងផ្តល់ជម្រើសចំណាត់ថ្នាក់មុខងារ មូលនិធិ និងគម្រោង (៤) សិក្សានិងផ្តល់ជម្រើសសម្រាប់ការឈានទៅប្រព័ន្ធគណនេយ្យបង្គរជាជំហានៗ។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្តគោលបំណងនេះសម្រេចបាន ៦៧% ក្នុងនោះ ចង្កោមសកម្មភាព២១.២ សម្រេចបាន ៩៣%, ២១.១ សម្រេចបាន ៧៧%, ២១.៤ សម្រេចបាន ៧០% ២១.៣ សម្រេបាន៦០%។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗ ដែលសម្រេចបានជាវិជ្ជមានតាមគោលដៅ គឺ (១)ប្លង់គណនីថ្មីត្រូវបានដាក់ឲ្យអនុម័ត និងអនុវត្ត និង (២) ជម្រើសចំណាត់ថ្នាក់មុខងារ ប្រភពធនធាន និងគម្រោងត្រូវបានសិក្សា ដើម្បីត្រៀមដាក់ឱ្យអនុវត្ត។ ផ្ទុយទៅវិញ ការងារដែលហាក់នៅមានភាពយឺតយ៉ាវ និងដែលត្រូវបន្តពង្រឹង គឺការអនុម័តចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច។ សេចក្តីព្រាងចុងក្រោយនៃការកែសម្រួលគោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌមាតិកាថវិកាថ្មីត្រូវបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និង របាយការណ៍តាមស្តង់-ដារ IPSAS Cash Basis ត្រូវបានរៀបចំអនុវត្តសាកល្បង។ ទម្រង់របាយការណ៍តាមស្តង់ដារ IPSAS Cash Basis បានរៀបចំរួចរាល់ហើយ ប៉ុន្តែមិនអាចដកស្រង់ទិន្នន័យសម្រាប់បំពេញឱ្យបានពេញលេញនៅឡើយ។

យោងតាមលទ្ធផលខាងលើនេះ ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មីសម្រាប់ជំហានទី១ នៃប្រព័ន្ធ FMIS ទំនងជាអាចប្រព្រឹត្តទៅបានទាន់ពេលតាមការគ្រោងទុក ដោយសមាសធាតុចាំបាច់មួយចំនួន សម្រាប់អនុវត្តប្រព័ន្ធ FMIS អាចប្រើប្រាស់បាន។ ជាមួយគ្នានេះដែរ ភាពចាំបាច់ក្នុងការពន្លឿនការឱ្យអនុវត្តចំណាត់ថ្នាក់ថវិកាពេញលេញយ៉ាងតិច៤ គឺចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច, សិក្សា និងដាក់ឱ្យអនុវត្តបន្ថែមចំណាត់ថ្នាក់មុខងារ មូលនិធិ និងគម្រោង និងបញ្ចប់ការរៀបចំបាយការណ៍តាមស្តង់ដារ IPSAS Cash Basis ឱ្យបានពេញលេញ។

**<u>២.២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី</u>**

ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងបន្តអនុវត្តនៅឆ្នាំ២០១៤ ដោយបានកែលម្អចង្កោមសកម្មភាពមួយចំនួន។ ដោយឡែកសម្រាប់ឆ្នាំ២០១៣ វឌ្ឍនភាព មួយចំនួនត្រូវបានសង្កេតឃើញ គឺការកែលម្អដំណើរការនៃកិច្ចប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ចំណាយដើម្បីឱ្យស្របទៅនឹងការបង្កើតប្លង់គណនេយ្យ និងវិធានគណនេយ្យ ព្រមទាំងការប្រមូលផ្តុំគណនេយ្យធនាគារជាប្រចាំ, ការកសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS។ ផ្ទុយទៅវិញ ការរៀបចំផែនការបណ្តុះបណ្តាល ព្រមទាំងឯកសារបណ្តុះបណ្តាលមន្ត្រីដែលពាក់ព័ន្ធនឹង FMIS បានអនុវត្តទៅយឺតជាងផែនការ។

ជាវិធានការបន្ត និងកំណត់ឡើងវិញពីតួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងការរៀបចំបង្កើតសៀវភៅគោលស្តីពីការណែនាំនីតិវិធីចំណាយ និងបែបបទត្រួតពិនិត្យហិរញ្ញវត្ថុថវិកាតាមកម្មវិធីរបស់អង្គភាពថវិកា។

បើពិនិត្យមើលចង្កោមសកម្មភាពទាំង៧ នៅក្នុងឆ្នាំ២០១៤ ឃើញថាកិច្ចការសំខាន់ៗចំនួនត្រូវបានកំណត់សម្រាប់ប្រព័ន្ធ និងដំណើរការអនុវត្តថវិកាថ្មីប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្ត គោលបំណងនេះសម្រេចបាន៧៨% ក្នុងនោះ ចង្កោមសកម្មភាព២២.១ សម្រេចបាន៩៣%, ២២.២ សម្រេចបាន៨៦%, ២២.៣. សម្រេចបាន៨៣%, ២២.៤. សម្រេចបាន ៨៥%, ២២.៥. សម្រេចបាន ៨៧%, ២២.៦ សម្រេចបាន ៥០%, និង ២២.៧. សម្រេចបាន ៦៣%។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗដែលមានការវិវឌ្ឍប្រសើរជាងឆ្នាំកន្លងទៅរួមមាន (១) នីតិវិធីនៃការអនុវត្តថវិកាត្រូវបានកាត់បន្ថយជាអតិប្បរមា (២) ឯកសារគតិយុត្តសំខាន់ៗត្រូវបានធ្វើបច្ចុប្បន្នភាព សម្រាប់ពង្រឹងការអនុវត្តថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យស្របតាមការវិវឌ្ឍនៃប្លង់គណនេយ្យ (៣) សមត្ថភាពមន្ត្រីក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបានបង្កើន និង(៤) ផែនការគ្រប់គ្រងគម្រោង FMIS រួមត្រូវបានរៀបចំគ្រប់ជ្រុងជ្រោយ។ ផ្ទុយទៅវិញ កិច្ចការមួយចំនួនពាក់ព័ន្ធនឹងការអនុម័តផែនការបណ្តុះបណ្តាលរួមសម្រាប់គម្រោង FMIS ដំណាក់កាលទី១ និងឯកសារនីតិវិធីអនុវត្តការងារអនាគត និងគ្រោងប្លង់នីតិវិធីអនុវត្តការងារក្នុងប្រព័ន្ធ FMIS នៅមានភាពយឺតយ៉ាវនៅឡើយ។ ជាវិធានការបន្ត ដើម្បីអាចរៀបចំនិងដាក់ឱ្យអនុវត្ត (Go Live) នេះបានតាមពេលវេលាកំណត់បាន អគ្គនាយកដ្ឋាន/អង្គភាពគន្លឹះ ដែលមានភារៈកិច្ចទទួលបន្ទុករៀបចំគម្រោង FMIS ត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងគោរពប្រតិបត្តិគោលការណ៍និងមុខងារនៃការទទួលខុសត្រូវ ជាពិសេស ត្រូវហ៊ានទទួលស្គាល់សម្រាប់ការកែលម្អ និងជោគជ័យ។

## ២.៣. ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព

ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងត្រូវអនុវត្តនៅឆ្នាំ២០១៤ បន្តទៀត។ដោយឡែក សម្រាប់ឆ្នាំ២០១៣ មានសកម្មភាពជាច្រើនសម្រេចបានជាវិជ្ជមាន សម្រាប់គាំទ្រដល់គោលបំណងនេះ តួយ៉ាងសកម្មភាពសម្រាប់បន្តពង្រីកវិសាលភាព ការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល-ចំណាយថវិកា និងការតាមដានអាណត្តិមិនទាន់ទូទាត់ និងអាយុកាលរបស់វា ព្រមទាំងទឹកប្រាក់ត្រូវសងត្រូវបានពង្រឹងយ៉ាងមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ សកម្មភាព សម្រាប់បម្រើគោលដៅក្នុងការប្រមូលផ្តុំគណនីធនាគាររដ្ឋាភិបាល និងពង្រឹងគណនីទោលរតនាគារ (TSA) នៅមិនទាន់សម្រេចបានចប់សព្វគ្រប់។ ជាមួយគ្នានេះ បញ្ហាប្រឈមមួយចំនួនត្រូវបានសង្កេតឃើញថា ក្រៅពីកង្វះសម្ភារៈ និងថវិកា ការងារមួយចំនួននៅមិនទាន់អនុវត្តតាមផែនការដូចជា ការសិក្សា និងពិនិត្យឡើងវិញនូវការលទ្ធភាពប្រមូលផ្តុំគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងរចនាសម្ព័ន្ធគណននីទៅ ដោយសារការប្រមូលផ្តុំគនណីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ទៅក្នុងរចនាសម្ព័ន្ធគណនីទោល គឺជាបញ្ហាប្រឈមដែលមានលក្ខណៈស្មុគស្មាញ ដោយមិនមានមូលដ្ឋាន និងប្រភពច្បាស់លាស់ក្នុងការពិនិត្យតាមដាន ផ្សេងវិញទៀត ផែនការជាជំហានៗ សម្រាប់អនុវត្តគណនីបង្គរត្រូវការប្រើរយៈពេលយូរលើសពី៥ ឆ្នាំ។ ជាវិធានការបន្ត ការងារចាំបាច់មួយចំនួនត្រូវបានកំណត់ដូចជា ការប្រមូលផ្តុំ និងពង្រឹងបន្ថែមការធ្វើផែនការសាច់ប្រាក់, កសាងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដោយមានគោលការណ៍ និងនីតិវិធីសម្រាប់អង្គភាពពាក់ព័ន្ធ

ដើម្បីបង្កើតការព្យាករណ៍លំហូរសាច់ប្រាក់ និងការព្យាករណ៍សមតុល្យប្រាក់ចុងថ្ងៃ នៅគណនីទោលរតនាគារឱ្យមានភាពត្រឹមត្រូវ និងទាន់ពេលវេលា។

បើពិនិត្យមើលចង្កោមសកម្មភាពក្នុងឆ្នាំ២០១៤ ការងារសំខាន់ៗត្រូវបានកំណត់ និងដាក់ឱ្យអនុវត្ត (១) ការពិនិត្យឡើងវិញនូវស្តង់ដារគណនេយ្យ រដ្ឋបាលសាធារណៈ ដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAPP) និងវាយតម្លៃភាពប្រាកដនិយម និងភាពសមស្របនៃលំដាប់លំដោយក្នុងការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យនេះ ដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS (២) ដាក់ឱ្យអនុវត្តនូវរបាយការណ៍អនុវត្តថវិកាថប្រចាំត្រីមាសដែលបញ្ជាក់អំពីការងារដែលបានបំពេញធៀបនឹងគោលដៅលទ្ធផលទទួលបាន ការយឺតយ៉ាវ និងវិធានការដោះស្រាយ (៣) កែលម្អទម្រង់របាយ-ការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ (៤) កែលម្អទម្រង់របាយការណ៍និងការផ្លាស់-ប្តូរព័ត៌មានជាមួយសាធារណជន និង (៥) ដាក់ឱ្យអនុវត្តយន្តការ ដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្ត គោលបំណងនេះសម្រេចបាន៧៤%ក្នុងនោះចង្កោមសកម្មភាព២៣.៥ សម្រេចបាន១០០% និងចង្កោមសកម្មភាព ២៣.១ សម្រេចបាន៨៨%។ ចំណែកឯចង្កោមសកម្មភាព២ ទៀតគឺ ២៣.៣ និង ២៣.៤ អគ្គនាយកដ្ឋានពាក់ព័ន្ធមិនទាន់បានរៀបចំផែនការសកម្មភាពលម្អិតសម្រាប់គាំទ្រទេ ប៉ុន្តែចំពោះចង្កោមសកម្មភាព ២៣.៣ នាយដ្ឋានបានរាយការណ៍ពីផែនការសម្មភាព និងលទ្ធផលសម្រេចបានតាមចង្កោមសកម្មភាពនេះ បើទោះបីជាអគ្គនាយដ្ឋានមិនបានគ្រោងសកម្មភាពទុកជាមុនក៏ដោយ។

ផ្អែកតាមលទ្ធផលខាងលើ វឌ្ឍនភាពដែលសម្រេចបាន គឺសេចក្តីព្រាងសារាចរណែនាំស្តីពីបញ្ជីសារពើភ័ណ្ឌដោយដាក់តម្លៃត្រូវបានពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ ស្តង់ដារគណនេយ្យបច្ចុប្បន្ន ត្រូវបានសិក្សាវាយតម្លៃ និងបន្តកែលំអឲ្យស្របតាមស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិពុំទាន់អនុវត្តបានគ្រប់ ជ្រុងជ្រោយនៅឡើយទេ។

ជាវិធានបន្ត តាមរយៈលទ្ធផលនេះ អគ្គនាយកដ្ឋានពាក់ព័ន្ធចាំបាច់ត្រូវរៀបចំសកម្មភាពលម្អិតក្នុងការគាំទ្រគោលបំណងសម្រាប់ដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព ដូចបានកំណត់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។

**<u>២.៤. ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព</u>**

ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងត្រូវអនុវត្តនៅឆ្នាំ២០១៤ បន្តទៀត។ ដោយឡែក សម្រាប់ឆ្នាំ២០១៣វឌ្ឍនភាពមួយចំនួនត្រូវបានសង្កេតឃើញដូចជាការធ្វើការត្រួតពិនិត្យជាប្រចាំចំពោះការអនុវត្តបទដ្ឋានគ្រប់គ្រងធនធានរបស់អង្គភាពថវិកា ដើម្បីធ្វើការមូលដ្ឋានក្នុងការពង្រីក ការផ្តល់សិទ្ធិអំណាច និងភាពទន់ភ្លន់។ ផ្ទុយទៅវិញ ការបង្កើតឱ្យមានវិធានការពិន័យ និងការដាក់ទណ្ឌកម្មសមស្របចំពោះការគ្រប់គ្រងធនធានមិនសមស្រប ឬ គ្មានប្រសិទ្ធភាព រាប់ទាំងការដាក់បញ្ចូលវិធានការនានាទៅក្នុងច្បាប់និងធ្វើការណែនាំផ្សព្វផ្សាយឱ្យបានទូលាយ អនុវត្តបានទៅតិចតួច និងហាក់នៅឆ្ងាយពីផែនការសកម្មភាពដែលបានគ្រោងទុក។

សម្រាប់ឆ្នាំ២០១៤ ចង្កោមសកម្មភាពចំនួន ៤ បានផ្តោតទៅលើ (១)ការបង្កើតឱ្យមានទណ្ឌកម្មសមស្របចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងច្បាប់និងធ្វើការផ្សព្វផ្សាយនិងណែនាំឱ្យបានទូលំទូលាយ (២) រៀបចំឱ្យមានតារាងបញ្ជាក់អំពីសិទ្ធិ អំណាច និងភាពទន់ភ្លន់ដែលនឹងផ្តល់ជូនអង្គភាពថវិកាដែលបានបំពេញលក្ខណៈវិនិច្ឆ័យ ដែលមានការឯកភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានសាធារណៈដ៏ត្រឹមត្រូវ (៣) ធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំលើលទ្ធផលនៃការគ្រប់គ្រងធនធានដែលសម្រេចបានដោយអង្គភាពថវិកានីមួយៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្តល់សិទ្ធិអំណាចនិងភាពទន់ភ្លន់ និង(៤) ដាក់ឱ្យអនុវត្តនូវរបាយការណ៍អនុវត្តថវិកាប្រចាំត្រីមាស ដែលបញ្ជាក់អំពីការងារដែលបានបំពេញធៀបនឹងគោលដៅលទ្ធផល ទទួលបានការយឺតយ៉ាវនិងវិធានការដំណោះស្រាយ÷ ពីក្រសួង-ស្ថាប័ន មក កសហវ និងនៅផ្ទៃក្នុងក្រសួងស្ថាប័ន ពីអង្គភាពថវិការហូតដល់ថ្នាក់ដឹកនាំ។ ជារួម បើផ្អែកលើសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំនេះ គោលបំណងនេះសម្រេចបានត្រឹម ២៣% ក្នុងនោះចង្កោមសកម្មភាព ២៤.១ សម្រេចបាន ៩០% រីឯ ចង្កោមសកម្មភាព ៣ ទៀត គឺ ២៤.២, ២៤.៣ និង ២៤.៤ មិនមានសកម្មភាពអនុវត្តទេ។

ផ្អែកតាមលទ្ធផលខាងលើ គោលបំណងនេះដែលគួរត្រូវរៀបចំសកម្មភាពឱ្យបានច្រើន តែជាក់ស្តែងសកម្មភាពដែលបានអនុវត្ត និងលទ្ធផលដែលទទួលបាននៅមានកម្រិតទាបខ្លាំង ដែលជាក្តីបារម្ភសម្រាប់ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានសាធារណៈ និងវិន័យមន្ត្រីសាធារណៈពុំត្រូវបានបង្កើនស្របតាមនិន្នាការនៃការកែទម្រង់ប្រព័ន្ធថវិកាដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ។ ជាការសន្និដ្ឋាន សម្រាប់គោលបំណងនេះ នៅមានកិច្ចការជាច្រើនដែលត្រូវបន្តពង្រឹងពាក់ព័ន្ធនឹងបទបញ្ជាផ្ទៃក្នុងគ្រប់នាយកដ្ឋាន អង្គភាព ក្រោមឱវាទ, គោលការណ៍ស្តីពីសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកា ព្រមទាំងការពង្រឹងការត្រួតពិនិត្យឡើងវិញជាប្រចាំលើលទ្ធផលនៃការគ្រប់គ្រងធនធាន ដែលសម្រេចបានដោយអង្គភាពថវិកានីមួយៗ នៅតាមគ្រប់ក្រសួង ស្ថាប័ន។

**<u>២.៥. ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា</u>**

ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងត្រូវអនុវត្តនៅឆ្នាំ២០១៤ បន្តទៀត។ ដោយឡែក សម្រាប់ឆ្នាំ២០១៣វឌ្ឍនភាពមួយចំនួនត្រូវបានសង្កេតឃើញដូចជា ការរៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្មថវិកា, បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSPs) និងថវិកាតាមកម្មវិធី (BP), ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រទៅក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី។ ផ្ទុយទៅវិញ ការបន្តបញ្ចូលចំណូល ចំណាយដែលនៅក្រៅបរិបថ ថវិកាទៅក្នុងថវិកាប្រចាំឆ្នាំរួមទាំងការបង្កើនជាបណ្តើរៗនូវការបញ្ចូលមូលនិធិដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ ទោះបីជាសម្រេចបានការងារច្រើន ប៉ុន្តែនៅមិនទាន់សម្រេចបានជាស្ថាពរ តាមផែនការដែលបានគ្រោងទុកនៅឡើយទេ។

សម្រាប់ឆ្នាំ២០១៤ នេះ សកម្មភាពនេះត្រូវបានបន្តអនុវត្តដើម្បីពង្រឹង(១) រៀបចំគោលនយោបាយ សម្រាប់ធ្វើសមាហរណកម្មថវិកា, បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈ

ពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាតាមកម្មវិធី (BP), ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រទៅក្នុងគោលការណ៍ណែនាំស្ដីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និង (២) បន្តបញ្ចូលចំណូលចំណាយដែលនៅក្រៅបរិបថថវិកាទៅក្នុងថវិកាប្រចាំឆ្នាំរួមទាំងការបង្កើនជាបណ្ដើរៗនូវការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងឆ្នាំ២០១៤ គោលបំណងនេះសម្រេច ១០០% ក្នុងនោះ ចង្កោមសកម្មភាពដែលអនុវត្តទៅសម្រេចតាមផែនការគឺ ២៥.១ ដោយឡែក ចង្កោមសកម្មភាព ២៥.២ មិនទាន់មានសកម្មភាពដែលអាចវាស់វែងបានទេ ព្រោះសកម្មភាពទាំងនោះ ត្រូវអនុវត្តនៅឆ្នាំ២០១៥។

ផ្អែកតាមលទ្ធផលខាងលើនេះ សកម្មភាពដែលគួរឱ្យកត់សម្គាល់ និងសម្រេចទៅបានតាមផែនការ គឺ "លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដាក់ពិន្ទុ និងវិធីសាស្ត្រចាត់ថ្នាក់លើការរៀបចំ BSP ត្រូវបានកែសម្រួល"។ ទោះជាយ៉ាងណាគោលបំណងនេះចាំបាច់តម្រូវឱ្យអគ្គនាយកដ្ឋានពាក់ព័ន្ធត្រូវបន្តខិតខំអនុវត្ត តាមរយៈការរៀបចំ ផែនការសកម្មភាព និងសូចនាករ ឱមានសុក្រិតភាព និងសង្គតិភាព បន្ថែមទៀត និង គោលការណ៍ យន្តការ នីតិវិធី និង ក្របខណ្ឌគតិយុត្តសម្រាប់ធានាសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយនៃថវិកា ដើម្បីដាក់ឱ្យអនុវត្តឆមាសទី២ ឆ្នាំ២០១៥ ជាពិសេសការធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធន និងការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ។

## ២.៦. ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

ការដាក់ឱ្យពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ ២០១៣ និងត្រូវអនុវត្តនៅឆ្នាំ២០១៤ បន្តទៀត។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ ទោះបីជាពុំមានចង្កោមសកម្មភាពណាមួយបញ្ចប់បានជាស្ថាពរក៏ពិតមែន ប៉ុន្តែវឌ្ឍនភាពមួយចំនួនត្រូវបានសង្កេតឃើញទៅលើការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួង និងធានាប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង និងការកែលម្អសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច។ ផ្ទុយទៅវិញ នៅសល់ការងារដែលបន្តពង្រឹងពីការកែលម្អយន្តការ ដើម្បីធានាការឆ្លើយតបដើម្បីប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចទៅតាមបណ្ដាអង្គភាពថវិកា។ ជាមួយគ្នានេះ បញ្ហាប្រឈមមួយចំនួនត្រូវបានរំលេចឡើងដែលអង្គភាពពាក់ព័ន្ធពុំបានអនុវត្តតាមផែនការនោះ គឺការរៀបចំសេចក្តីព្រាងនីតិវិធីនៃទណ្ឌកម្មទៅតាមកម្រិតនៃកំហុសឆ្គងតាមច្បាប់ស្តីពីលក្ខន្តិកៈច្បាប់មន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនអាចអនុវត្តបានទាន់ពេលវេលា ដោយសារខ្វះខាតឯកសារគតិយុត្តគាំទ្រ។ ជាវិធានការបន្ត ថ្នាក់ដឹកនាំក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈបង្កើនការយកចិត្តទុកចិត្តទុកដាក់ដល់មុខងារសវនកម្មផ្ទៃក្នុង ពិសេស ក្នុងការជំរុញការផ្ញើផែនការ និងរបាយការណ៍សវនកម្មទៅអាជ្ញាធរសវនកម្មជាតិ និងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតម្រូវការកែសម្រួល និងបង្កើតសកម្មភាពមួយចំនួននៅក្នុង CAP 3 សម្រាប់បង្កើនយន្តការ ដើម្បីសម្របទៅតាមបច្ចេកវិទ្យាព័ត៌មាន។

សម្រាប់ឆ្នាំ២០១៤ វិញ សកម្មភាពនេះត្រូវបានបន្តអនុវត្តដើម្បីពង្រឹងលើ (១) ដំណើរការពេញលេញអង្គភាពសវនកម្មផ្ទៃនៅគ្រប់ក្រសួង-ស្ថាប័ន (២) កែលម្អយន្តការ ដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចនៅតាមបណ្ដាអង្គភាពថវិកា (៣)រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យដែលបានផ្តល់អនុសាសន៍ដោយ កសហវ និង

(៤) កសហវ ពិនិត្យមើលឡើងវិញពី ភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/អធិការកិច្ចនិងធ្វើការកែលម្អ។ ជារួម គោលបំណងនេះសម្រេចបានត្រឹម ៨០% ជាក់ស្តែងចង្កោមសកម្មភាព ២៦.១ សម្រេចបាន ៧៩%, ២៦.២ សម្រេចបាន ៨០%, ២៦.៣. សម្រេចបាន ៧៧%, និង ២៦.៤. សម្រេចបាន ៩០%។

ផ្អែកតាមលទ្ធផលខាងលើ ពុំមានចង្កោមសកម្មភាពណាមួយសម្រេចបានគ្រប់គ្រាន់តាមផែនការដែលបានគ្រោងទុកនៅឡើយទេ ហើយកិច្ចការដែលត្រូវបន្តពង្រឹងនោះរួមមាន (១) ក្រសួង ស្ថាប័នចំនួន ៨ ដែលអនុវត្តថវិកាកម្មវិធីពេញលេញគួរត្រូវបានពិនិត្យប្រសិទ្ធភាពការអនុវត្តសវនកម្ម (២) សវនដ្ឋាន ៣ គោលដៅត្រូវបានពិនិត្យ និងតាមដានការអនុវត្តអនុសាសន៍របស់ NAA (៣) ផ្សព្វផ្សាយទម្រង់តេស្តគុណភាពលើរបាយការណ៍ជូនក្រសួង ស្ថាប័ន និង (៤) ពិនិត្យ និងកែលម្អផែនការអធិការកិច្ចរបស់ក្រសួងស្ថាប័នដែលបានរៀបចំឡើង ដើម្បីឱ្យស្របតាមនីតិវិធី និងការណែនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មូលហេតុដែលធ្វើឱ្យលទ្ធផលខាងលើនេះមិនសម្រេចបានតាមផែនការ គឺភាគច្រើនអង្គភាពពាក់ព័ន្ធពុំបានរៀបចំផែនការថវិកា ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះឱ្យបានត្រឹមត្រូវ។

ដូចនេះ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតែមានដំណើរការល្អក្នុងការកែលម្អឱ្យស្របតាមបទដ្ឋានគតិយុត្ត និងស្តង់ដារ សម្រាប់ឆ្នាំ២០១៨ ក៏ប៉ុន្តែនៅមានការងារមួយចំនួនទៀតដែលចាំបាច់ត្រូវពង្រឹង និងពង្រីកដើម្បីបានឈានទៅសម្រេចតាមគោលដៅដែលបានគ្រោងទុក និងតម្រូវការជាក់ស្តែងក្នុងការបន្តបង្កើនឆន្ទៈ និងប្តេជ្ញាកែលម្អបន្ថែមទៀតលើរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃប្រព័ន្ធ និងយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការអនុវត្តថវិកា (ចំណាយ-ចំណូល) ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។

យើងអាចសន្និដ្ឋានបានថា សម្រាប់ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុកិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួន ត្រូវបានអនុវត្ត ជាពិសេស សមាសធាតុចាំបាច់មានដូចជាប្លង់គណនីថ្មី មាតិកាថវិកាថ្មី និងការងារកែលម្អការអនុវត្ត ថវិកាអាចយកមកប្រើប្រាស់បានសម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានទាន់ ពេលវេលាតាមកាលកំណត់។ ដើម្បីបន្តពង្រឹងផ្នែកនេះ ទិសដៅជាក់លាក់មួយចំនួនបាននិងកំពុងរៀបចំនៅក្នុងក្របខ័ណ្ឌរួមនៃ CAP 3 ពោលគឺ ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្តត្រូវបានដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០១៨ (ចំណាត់ថ្នាក់ថវិកា ប្លង់គណនេយ្យ និងការអនុវត្ត FMIS ដំណាក់កាលទី១ និងទី ២) រួមទាំងប្រព័ន្ធគណនេយ្យ និងប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព សុក្រឹតភាព និងទាន់ ពេលវេលា។

## ៣.ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់

ផ្នែកទី៣ នៃផែនការសកម្មភាពរួម ជាផែនការសកម្មភាពដែលត្រូវបានអនុវត្តតាំងពី CAP 2 មានគោលបំណងចំនួន២ ដោយបានផ្តោតទៅលើការត្រៀមលក្ខណៈសម្រាប់ជំហានទី ៣ និងទី៤ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ដែលត្រូវបន្តអនុវត្តជាបណ្តើរៗ នៅក្នុងដំណាក់កាលទី២ ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ទាំងមូល។ ជាក់ស្តែង បើយើងពិនិត្យមើលថយក្រោយបន្តិចទៀត

ឃើញថា ការត្រៀមលក្ខណៈសម្រាប់ជំហានទី២ នៅក្នុងដំណាក់កាលទី១ ពិតជាបានរួមចំណែកដ៏សំខាន់ក្នុងការធានានិរន្តរភាពនៃការកែទម្រង់។ ហើយនៅក្នុងដំណាក់ទី ២ នេះ គោលដៅចម្បងបានផ្តោតទៅលើការបន្តពង្រឹង និងពង្រីកភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា ជាពិសេស ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅក្រសួង ស្ថាប័នចំនួន១០ និងអង្គភាពថវិកានៅឆ្នាំ២០១៥។ ផ្អែកតាមលទ្ធផលចង្កោមសកម្មភាពដែលសម្រេចបានកាលពីឆ្នាំ២០១៣ ផ្នែកនេះ អនុវត្តទៅបាន៨៨% នៃគោលដៅចង្កោមសកម្មភាពដែលបានអនុវត្ត។ តាមការវាយតម្លៃជារួម ភាគច្រើននៃសកម្មភាពនៃផ្នែកនេះ សម្រេចបានជាវិជ្ជមានច្រើន ប៉ុន្តែ សារៈសំខាន់នៃផ្នែកនេះក្នុងឆ្នាំកន្លងទៅ ភាគច្រើនផ្តោតទៅលើភាពច្បាស់លាស់នៃគោលការណ៍ណែនាំ ការបណ្តុះបណ្តាល ការបណ្តុះឆន្ទៈ និងសមត្ថភាពរបស់មន្ត្រីគ្រប់ផ្នែក។យ៉ាងណាមិញ បើផ្អែកតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៣-២០២០ ឃើញថា សកម្មភាពមួយចំនួនអាចនៅមានការយឺតយ៉ាវ ក៏ប៉ុន្តែការត្រៀមលក្ខណៈ ពិតជាសម្រេចបានសមស្រប និងគ្រប់គ្រាន់នៅក្នុងរយៈកាលកន្លងមកនេះ។

សម្រាប់ឆ្នាំ២០១៤ នេះវិញ ផ្នែកនេះត្រូវគាំទ្រដោយគោលបំណងចំនួន៤ និងចង្កោមសកម្មភាពចំនួន១៩ ដែលផ្តោតទៅលើ (១) ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី (២) រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិរវាង កសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង-ស្ថាប័ន) (៣) ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ និង (៤) ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដែលជាការបន្តត្រៀមលក្ខណៈសម្រាប់ជំហានទី៣ ហើយនឹងត្រូវបន្តអនុវត្តរហូតដល់ឆ្នាំ២០១៥ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពវិភាជន៍ និងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាចាំបាច់ត្រូវមានសមាសធាតុថ្មីដែលត្រូវរាប់បញ្ចូលរួមមានផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និងអង្គភាពថវិកា។ ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់តាំងពីឆ្នាំ២០០៨ មក។ ជារួម ផ្អែកលើចង្កោមសកម្មភាពដែលបានកំណត់ ផ្នែកនេះសម្រេចបាន៨២% នៃគោលដៅចង្កោមសកម្មភាព។ ដូចនេះ ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់នៅក្នុងឆ្នាំ២០១៤ នេះសម្រេចបានការងារច្រើន តែចាំបាច់ត្រូវខិតខំពង្រឹងគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ សម្រាប់រយៈពេលមធ្យម និងវែង និងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីគួរត្រូវបានយកចិត្តទុកដាក់ និងពង្រឹងសកម្មភាពអនុវត្ត។

ចំណុចខាងក្រោមនេះ គឺជាការវាយតម្លៃអំពីវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅឆ្ពោះទៅមុខតាមគោលបំណងទាំង៤ សម្រាប់គាំទ្រឱ្យផ្នែកនេះ ដោយមិនត្រឹមតែឆ្លុះបញ្ចាំងអំពីរបាយការណ៍លទ្ធផលនៅឆ្នាំ២០១៤ ប៉ុណ្ណោះទេ ប៉ុន្តែ យើងក៏ឆ្លៀតពិនិត្យមើលអំពីស្ថានភាពដែលសម្រេចបាននៅឆ្នាំ២០១៣ ផងដែរ។

### ៣.១. ការពង្រឹង និងពង្រីកការអនុវត្តថវិកាតាមកម្មវិធី

ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី គឺជាចង្កោមសកម្មភាពដែលបានអនុវត្តពី CAP 2 នៅឆ្នាំ២០១៣ និងត្រូវអនុវត្តនៅឆ្នាំ២០១៤ បន្តទៀត។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ ទោះបីជាចង្កោមសកម្មភាពភាគច្រើនពុំទាន់

បានបញ្ចប់តាមផែនការនៅឡើយក្តី ប៉ុន្តែកិច្ចការសំខាន់ៗមួយចំនួនត្រូវបានអនុវត្តបានច្រើន ជាពិសេស ការអនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់អនុវត្តថវិកាកម្មវិធី និងការរៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកយុទ្ធសាស្ត្រថវិកាកម្មវិធី។ ផ្ទុយទៅវិញ នៅមានកិច្ចការមួយចំនួនទៀតត្រូវការពង្រឹងបន្ថែមដូចជាការពិនិត្យឡើងវិញ និងកែលម្អ និងអនុវត្តថវិកាកម្មវិធី។ ជាវិធានការបន្ត ការបើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយសារាចរណែនាំស្តីពីរបៀបនៃការអនុវត្តគោលការណ៍ណែនាំអង្គភាពថវិកា, ការរៀបចំក្របខ័ណ្ឌអង្គភាពថវិកា ការផ្លាស់ប្តូររបៀបការងារថ្មីរបស់ក្រសួងទាំង១០, វាយតម្លៃពីភាពខ្លាំង និងភាពខ្សោយ នៃគោលការណ៍ណែនាំ, របាយការណ៍ស្តីពីការអនុវត្តអង្គភាពថវិការបស់ក្រសួងសាកល្បងទាំង១០, ការបូកសរុបរបាយការណ៍ទាំងនោះ និងការផ្តល់អនុសាសន៍ដើម្បីកែលម្អគោលការណ៍ណែនាំ និងត្រូវបណ្តុះបណ្តាលក្រសួងសាកល្បងអនុវត្តអង្គភាពថវិកាទាំង១០ ខាងមុខ ឆាប់ៗនេះសិន។

សម្រាប់ឆ្នាំ២០១៤ ចង្កោមសកម្មភាពចំនួន ៣ ត្រូវបានដាក់ឱ្យអនុវត្តដែលផ្តោតទៅលើ (១) ពិនិត្យឡើងវិញ និងកែលម្អការអនុវត្តតាមកម្មវិធី (២) ការរៀបចំយុទ្ធសាស្ត្រថវិកាតាមកម្មវិធី និង (៣) អនុវត្តផែនការបណ្តុះបណ្តាលនិងកសាងសមត្ថភាពសម្រាប់អនុវត្តថវិកាកម្មវិធី។ ជារួម ផ្អែកលើសកម្មភាពដែលលបានអនុវត្ត ផ្នែកនេះ សម្រេចបាន ៨០% ក្នុងនោះ ចង្កោមសកម្មភាព ៣១.៣ សម្រេចបាន១០០% , ចង្កោមសកម្មភាព ៣១.១ សម្រេចបាន ៦០% និងដោយឡែកចង្កោមសកម្មភាព ៣១.២ ដែលបានរៀបចំពុំទាន់ដល់ពេលអនុវត្ត។

ផ្អែកតាមលទ្ធផលខាងលើ វឌ្ឍនភាពធំៗ មួយចំនួន ត្រូវសម្រេចបានតាមផែនការរួមមាន (១) “គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីតាមវិស័យបានកែលម្អ” និង (២) ឯកសារបង្រៀននៃថវិកាកម្មវិធីបានធ្វើបច្ចុប្បន្នភាព និងបានបណ្តុះបណ្តាលដល់គ្រូបង្គោល និងមន្ត្រីមកពីក្រសួងស្ថាប័នដែលអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៥ និងត្រៀមអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៦ ចំនួនសរុបទាំងអស់ ១២៥០ នាក់។ ផ្ទុយទៅវិញ សកម្មភាពដែលពុំសម្រេចបានតាមផែនការ គឺដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធី។ ការមិនសម្រេចតាមគោលដៅនេះដោយសារការរៀបចំផែនការសកម្មភាព និងការកំណត់សូចនាករមិនមានសុក្រឹតភាព ជាពិសេស បញ្ហាការកំណត់ពេលវេលា សម្រាប់អនុវត្តពុំមានច្បាស់លាស់។ ប៉ុន្តែ គោលការណ៍នេះ ត្រូវបានអគ្គនាយកដ្ឋានពាក់ព័ន្ធ លើកសំណើ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចនៅដើមខែមករា ឆ្នាំ២០១៥។ ម្យ៉ាងទៀត ការរៀបចំយុទ្ធសាស្ត្រថវិកាតាមកម្មវិធី ទោះបីជាមិនទាន់ដល់ពេលអនុវត្តនៅក្នុងផែនការសកម្មភាពក្នុងឆ្នាំ២០១៤ ក៏ដោយ ក៏ក្នុងគោលដៅពង្រីកការអនុវត្តថវិកាកម្មវិធី, ក្រសួងស្ថាប័នដែលគ្រោងនឹងចូលរួមអនុវត្តនៅឆ្នាំ២០១៦ ត្រូវបានផ្តល់ជំនួយបច្ចេកទេសជាបន្តបន្ទាប់។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី ត្រូវបានអនុវត្តតាមគោលដៅសម្រាប់ឆ្នាំ២០១៤ ទោះបីជាសូចនាករមួយចំនួនសម្រេចបានមិនពេញលេញ ជាពិសេសស ភាពយឺតយ៉ាវនៃការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីនិងការយល់ដឹងពីថវិកាកម្មវិធីរបស់ក្រសួងស្ថាប័នដែលស្ម័គចិត្តអនុវត្តថវិកាតាមកម្មវិធីឆ្នាំ២០១៦នៅមានកម្រិត។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបញ្ចប់ និងដាក់អនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាកម្មវិធីនៅដើមឆ្នាំ២០១៥ នេះប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព និងស្នើឱ្យក្រសួងស្ថាប័នដែលគ្រោងអនុវត្តថវិកាតាមកម្មវិធីត្រៀមរៀបចំផែនការសកម្មភាពទុកជាមុន។

**៣.២.រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន)**

រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព គឺជាចង្កោមសកម្មភាពដែលបានអនុវត្តនៅក្នុងផ្នែកទី២ នៃ CAP 2 នៅឆ្នាំ២០១៣ ហើយត្រូវយកអនុវត្តបន្តនៅផ្នែកនេះ សម្រាប់ឆ្នាំ២០១៤ វិញ ដោយបានកែលម្អចង្កោមសកម្មភាពមួយចំនួន។ ដោយឡែក សម្រាប់ឆ្នាំ២០១៣ សកម្មភាពដែលសម្រេចបានតាមផែនការគឺ ការងារពិនិត្យឡើងវិញនឹងធ្វើវិសោធនកម្មច្បាប់ ដែលកំណត់ពីតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ និងការរៀបចំវិនិយោគសាធារណៈ (PIP) និងកំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននីមួយៗ បានសម្រេចទៅចប់សព្វគ្រប់។ ផ្ទុយទៅវិញការរៀបចំតារាងបញ្ជាក់ពីសិទ្ធិអំណាច និងភាពទន់ភ្លន់ ដែលនឹងផ្តល់ជូនអង្គភាពថវិកា ហាក់នៅមានការយឺតយ៉ាវ និងពុំទាន់សម្រេចបានតាមផែនការ។ ជាវិធានបន្ត មានអនុសាសន៍មួយចំនួនត្រូវបានរំលេចឡើងដូចជា ការកំណត់ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យឱ្យមានភាពសមស្របទៅតាមថវិកាកម្មវិធី និងស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៣-២០២០។

សម្រាប់ឆ្នាំ២០១៤ នេះ សកម្មភាពត្រូវបន្តអនុវត្តដើម្បីពង្រឹងលើ (១) ការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មលើច្បាប់ និងបទបញ្ញត្តិដែលកំណត់តួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល (២) កំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ និងក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ និងកំណត់អំពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននីមួយៗ (៣) កំណត់អង្គភាពថវិកានិងអ្នកគ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិ (៤) កំណត់ពីការទទួលខុសត្រូវ និងការគ្រប់គ្រងគ្រប់កម្រិត (៥) រៀបចំ និងចេញផ្សាយកម្រងនីតិវិធីណែនាំ ពន្យល់ពីការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវ ដល់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា តាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា និង (៦) កែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មី ដោយកំណត់ឱ្យបានច្បាស់លាស់ពីតួនាទីក្នុងក្របខ័ណ្ឌវិមជ្ឈការ។ ជារួម គោលបំណងនេះសម្រេចបាន ៨៦% ក្នុងនោះចង្កោមសកម្មភាព៣២.៥ សម្រេចបាន ១០០%, ៣២.៣ សម្រេចបាន៩០%, ៣២.៦ សម្រេចបាន៧០%។ ដោយឡែក ចង្កោមសកម្មភាព ៣២.១ ពុំទាន់ដល់ពេលអនុវត្ត និងចង្កោមសកម្មភាព ៣២.២ និង ៣២.៤. អគ្គនាយដ្ឋានពាក់ព័ន្ធមិនបានរៀបចំផែនការសកម្មភាពលម្អិតសម្រាប់គាំទ្រនេះទេ។

ផ្អែកតាមលទ្ធផលខាងលើនេះ វឌ្ឍនភាពគួរឱ្យកត់សម្គាល់មានដូចជា បានពិនិត្យឡើងវិញក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តអំណាចហិរញ្ញវត្ថុទៅអង្គភាពថវិកា និងបានផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកាជូនក្រសួង-ស្ថាប័ន ដែលគ្រោងអនុវត្តថវិកាកម្មវិធី។ ផ្ទុយទៅវិញ សកម្មភាពដែលពុំបានអនុវត្តតាមផែនការកំណត់ គឺប្រកាសអន្តរក្រសួងស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាសម្រាប់ក្រសួងទាំង១០ ត្រូវបានរៀបចំ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់ក្រសួងស្ថាប័នត្រូវបានប្រតិភូកម្មអំណាចបន្ថែមក្នុងការចុះទិដ្ឋាការលើលិខិតធានាចំណាយ និងអាណត្តិបើកប្រាក់សម្រាប់មុខចំណាយមួយចំនួន និងក្នុងទំហំទឹកប្រាក់កំណត់។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងនេះត្រូវបានអនុវត្តទៅបានច្រើន ប៉ុន្តែពុំទាន់សម្រេចបានពេញលេញតាមផែនការដែលបានកំណត់នៅឡើយទេ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវរៀបចំផែនការសកម្មភាព និងសូចនាករឱ្យឆ្លើយតបទៅនឹងការកំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ និងក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ និងកំណត់អំពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននីមួយៗ និងបញ្ចប់ការរៀបចំដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងស្តីពីការទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាសម្រាប់ក្រសួងទាំង១០ ព្រមទាំងបញ្ចប់ការរៀបចំប្រកាសប្រតិភូកម្មអំណាចបន្ថែមដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់ក្រសួងស្ថាប័ន។

## ៣.៣. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ

ការពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ គឺជាចង្កោមសកម្មភាពដែលពុំត្រូវបានអនុវត្តនៅក្នុង CAP 2 នៅឆ្នាំ២០១៣ ទេ ហើយជាសកម្មភាពដែលត្រូវបានបង្កើតថ្មីនៅឆ្នាំ២០១៤ ដោយផ្តោតលើ (១) ការពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (២) ការពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម និង (៣) ពង្រឹងសមត្ថភាពវិភាគនិងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជារួម បើផ្អែកលើសកម្មភាព ដែលសម្រេចបាន គោលបំណងនេះ សម្រេចបានក្នុងរង្វង់ ៩៥% ក្នុងនោះ ចង្កោមសកម្មភាព ៣៣.១ សម្រេចបាន៩៥% និង ២ ចង្កោមសកម្មភាពទៀត ទោះបីជាមិនទាន់ដល់ពេលអនុវត្ត ក៏អគ្គនាយកដ្ឋានពាក់ព័ន្ធបានចាប់ផ្តើមអនុវត្តចង្កោមសកម្មភាពបានលទ្ធផលច្រើនជាបន្តបន្ទាប់។

ផ្អែកតាមលទ្ធផលខាងលើនេះ សកម្មភាពធំៗមួយចំនួន ត្រូវបានអនុវត្តដោយទទួលបានលទ្ធផលច្រើនដែលពាក់ព័ន្ធទៅនឹងទិន្នន័យនិងស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំនិងប្រមូលផ្តុំ។ ផ្ទុយទៅវិញ សកម្មភាពដែលពុំទាន់សម្រេចបានតាមផែនការមានដូចជាការរៀបចំក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម ២០១៥-២០១៧ ត្រូវបានពិនិត្យឡើងវិញ និង ត្រូវរៀបចំ ពីកម្រិតលើមកក្រោម (Top-Down Approach) និងតម្រូវការទិន្នន័យសម្រាប់ម៉ូដែលព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបញ្ចប់ការសិក្សាទម្រង់វិភាគនិងទិន្នន័យសារពើពន្ធត្រូវបានចងក្រងនិងរបាយការណ៍វិភាគសេដ្ឋកិច្ចប្រចាំឆ្នាំ។ ការមិនសម្រេចតាមគោលដៅនេះ ដោយសារកង្វះមន្ត្រីដែលជាហេតុនាំឱ្យការសិក្សារៀបចំសេចក្តីព្រាងយន្តការពង្រីកវិសាលភាព TOFE និង GFS ថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ, កង្វះខាតទិន្នន័យក្នុងការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ២០១៥-២០១៧ (MTEF) និងដំណើរការម៉ូដែលគោលនយោបាយនិងកម្មវិធីហិរញ្ញវត្ថុ (Financial Programming and Policies Model) មិនទាន់មានសង្គតិភាពល្អនៅឡើយ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា ការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តដោយទទួលបានលទ្ធផលវិជ្ជមានច្រើន ប៉ុន្តែចាំបាច់ត្រូវការបន្តពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម និងបន្តពង្រឹងសមត្ថភាពវិភាគ និងព្យាករណ៍

ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យកាន់តែប្រសើរឡើងថែមទៀត តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីភាពគ្រប់ជ្រុង-ជ្រោយនៃទិន្នន័យ និងការធានាសង្គតិភាពនៃម៉ូដែលថ្មីជាមួយស្ថានភាពដែលមានស្រាប់។

## ៣.៤. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ជាគោលបំណងដែលត្រូវបានដាក់ឱ្យអនុវត្តនៅក្នុង ផ្នែកទី ២ នៃ CAP 2 នៅឆ្នាំកន្លងទៅ ហើយត្រូវបន្តអនុវត្តនៅផ្នែកទី៣ នៃ CAP 2New នៅឆ្នាំ២០១៤ នេះបន្ថែមទៀត។ ផ្អែកតាមលទ្ធផលដែលសម្រេចបាននៅឆ្នាំ២០១៣ ជាទូទៅពុំមានចង្កោមសកម្មភាពណាមួយសម្រេចបានជាស្ថាពរនោះទេ ប៉ុន្តែមានចង្កោមសកម្មភាពខ្លះដែលអនុវត្តទៅបានច្រើនគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងពង្រឹងសមត្ថភាពក្នុងការរៀបចំ និងអនុវត្តថវិកា ព្រមទាំងប្រព័ន្ធហិរញ្ញវត្ថុ ក្របខណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ និងការសិក្សាពីការអនុវត្ត និងបង្កើតជម្រើសសម្រាប់ពង្រីកការរៀបចំ និងអនុវត្តថវិកាខេត្ត ក្រុង។ ផ្ទុយទៅវិញ និងអ្វីដែលជាក្តីបារម្ភ គឺការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុដោយផ្អែកលើក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែលម្អចំណូលមិនមែនសារពើពន្ធរបស់ខេត្ត ក្រុង ស្ថិតនៅស្ថានភាពដែលឆ្ងាយពីផែនការដែលបានដាក់ចេញ។

បើពិនិត្យមើលចង្កោមសកម្មភាពសម្រាប់ឆ្នាំ២០១៤ វិញ គោលបំណងនេះ ត្រូវគាំទ្រដោយចង្កោមសកម្មភាពចំនួន ៧ គឺ (១) បន្តរៀបចំអនុក្រឹត្យប្រកាសសារាចរ សេចក្តីណែនាំ ដែលតម្រូវដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២)រៀបចំនិងអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុ រយៈពេលមធ្យមនិងវែង (៣) បង្កើត និងកែលម្អឧបករណ៍ អភិបាលកិច្ចទ្រទ្រង់ការរៀបចំនិងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) សិក្សារៀបចំ និងអនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៥) បង្កើតឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) (៦) រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនិង (៧) រៀបចំផែនការកសាងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសទាក់ទិនទៅនឹងការអនុវត្ត FMIS។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន៦៨% ក្នុងនេះ ៣៤.៧, ៣៤.៣ និង ៣៤.៤ សម្រេចបាន១០០%, ចង្កោមសកម្មភាព ៣៤.១ សម្រេចបាន៨៤% និង ៣៤.៥ សម្រេចបាន៧០%។ ដោយឡែក ចង្កោមសកម្មភាព ២ ដែលសម្រេចបានតិចជាង ៥០% គឺ៣៤.៦ សម្រេចបាន២០% និង៣៤.២ ពុំមានសកម្មភាពអនុវត្តតាមផែនការដែលអគ្គនាយកដ្ឋានបានដាក់ចេញ។

ផ្អែកតាមលទ្ធផលខាងលើ ការងារសំខាន់ៗ ដែលសម្រេចបានជាវិជ្ជមានរួមមាន (១) លិខិតបទដ្ឋានគតិយុត្ត នីតិវិធីសម្រាប់ការអនុវត្តថវិកាថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល និងរៀបចំ (២) ឯកសារទស្សនទានស្តីអំពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបញ្ចប់ (៣) ផែនការកសាងសមត្ថភាពត្រូវបានរៀបចំ និងមន្ត្រីថ្នាក់ ជាតិទទួលបានការបណ្តុះបណ្តាលពិសេសទាក់ទងការអនុវត្ត FMIS។ ផ្ទុយទៅវិញ សកម្មភាពដែលពុំសម្រេចបានតាមផែនការរួមមាន (១) លិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលតម្រូវដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបន្តរៀបចំ ប៉ុន្តែមិនទាន់ចប់សព្វគ្រប់នៅឡើយ (២) ឯកសារគោលនយោបាយ

និងលិខិតបទដ្ឋានគតិយុត្តសម្រាប់បង្កើតឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់បានរៀបចំសព្វគ្រប់នៅឡើយ និង (៣) ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់បានរៀបចំសព្វគ្រប់នៅឡើយ។ ដោយឡែក ការរៀបចំសេចក្តីព្រាងបឋមឯកសារគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងវែង ពុំត្រូវបានអនុវត្តតាមផែនការ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ ដែលតម្រូវឱ្យអង្គភាពពាក់ព័ន្ធខិតខំបន្ថែមទៀត ជាពិសេស ពង្រឹងការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រយៈពេលមធ្យម និងវែង ហើយដើម្បីសម្រេចបានគោលបំណងនេះ អង្គភាពសាមី គួរស្នើសុំជំនួយបច្ចេកទេសបន្ថែមពីអគ្គនាយកដ្ឋានថវិកា ឬ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម សម្រាប់ការ ត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ សកម្មភាពភាគច្រើនសម្រេចបានតាមគោលដៅ ដែលភាគច្រើននៃកិច្ចការនេះផ្តោតលើ ការបន្តពង្រឹងភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា ជាពិសេស ការបង្រឹងការការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការបន្តពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី តែចាំបាច់ត្រូវខិតខំពង្រឹងការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ សម្រាប់រយៈពេលមធ្យម និងវែង និងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីគួរត្រូវបានយកចិត្តទុកដាក់ និងពង្រឹងសកម្មភាពអនុវត្ត ថវិកាកម្មវិធីពេញលេញ។ ដើម្បីបន្តពង្រឹងផ្នែកនេះ ទិសដៅជាក់លាក់មួយចំនួនបាននិងកំពុងរៀបចំនៅក្នុងក្របខ័ណ្ឌរួមនៃ CAP 3 ពោលគឺផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំ និងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព និងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី , ថវិកាកម្មវិធី និងអង្គភាពថវិកាត្រូវបានអនុវត្តគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព, ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) និងក្របខ័ណ្ឌចំណូលរយៈពេលមធ្យម-បីឆ្នាំរំកិល ( MTRF) ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាព ស័ក្តិសិទ្ធ។

## ៤. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព

ការគាំទ្រដក់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព ជាផ្នែកមួយថ្មីដែលចាប់ផ្តើមអនុវត្តស្របគ្នាជាមួយនឹងផ្នែកទាំង៣ ដូចបានរៀបរាប់ខាងលើ សម្រាប់ចូលរួមចំណែកនៅក្នុង CAP 2 New នៅឆ្នាំ២០១៤។ ដោយឡែក សកម្មភាពមួយចំនួនមិនមែនសុទ្ធតែថ្មីស្រឡាងនោះទេ ពោលគឺ សកម្មភាពមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងគោលបំណងទី២៨ នៃផ្នែកទី២ នៅក្នុង CAP 2 នៅឆ្នាំកន្លងទៅ តាមរយៈការរៀបចំស្ថាប័ន, ការអភិវឌ្ឍធនធានមនុស្ស និងការកសាងបណ្តុះបណ្តាលជំនាញ ,ការរៀបចំឱ្យមានការលើកទឹកចិត្ត ព្រមទាំងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងសម្របសម្រួលសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាពទៅនឹងដំណាក់កាលទី២។ តាមលទ្ធផល ដែលបានអនុវត្តនាឆ្នាំកន្លងមក ឃើញថា សកម្មភាពទាំងនេះសម្រេចបានក្នុងវង្វង់

៧៣% ដែលលទ្ធផលល្អប្រសើរមួយចំនួនត្រូវបានពង្រឹងទៅលើការកសាង និងបណ្ដុះបណ្ដាលជំនាញតាមរយៈការរៀបចំវគ្គសិក្សា និងសិក្ខាសាលា។ ផ្ទុយទៅវិញ ការងារដែលទាមទារឱ្យមានការពង្រឹងបន្ថែមនោះគឺការរៀបចំឱ្យមានប្រព័ន្ធលើកទឹកចិត្ត តាមរយៈការរៀបចំប្រាក់រង្វាន់ គាំទ្រដល់ការផ្លាស់ប្តូរដំណើរការ និងស្ថាប័ន និងការយល់ដឹង រួមទាំងការចូលរួមក្នុងផែនការកសាងសមត្ថភាព។

សម្រាប់ឆ្នាំ២០១៤ នេះ ផ្នែកនេះត្រូវបានគាំទ្រដោយគោលបំណងចំនួន២ គឺ (១) បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្ដុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ និង (២) បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត។ មានន័យថា ផ្នែកទាំង៣ ដែលយើងបានខិតខំកសាង និងពង្រឹងនៅក្នុងដំណាក់កាលទី២ នេះគឺជាការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីឈានទៅរកស្តង់ដារអន្តរជាតិ, ការកសាងនូវយន្តការ និងការរៀបចំចងក្រងនូវបទដ្ឋានគតិយុត្តដើម្បីពង្រឹងដល់ការអនុវត្តដល់កិច្ចដំណើរការនៃប្រព័ន្ធទាំងមូលឱ្យមានភាពប្រឡាក់ក្រឡាគ្នា ប៉ុន្តែការកសាងទាំងអស់មិនទាន់មានលក្ខណៈគ្រប់គ្រាន់ឡើយ ដែលចាំបាច់ទាមទារអ្នកដឹកនាំ និងអ្នកចូលរួមបញ្ជ្រាបចូលទៅក្នុងប្រព័ន្ធនេះ ហើយអាចអនុវត្តនិងប្រតិបត្តិទៅតាមមុខងារនិងតួនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ជារួមផ្នែកលើចង្កោមសកម្មភាពដែលបានអនុវត្តធៀបទៅនឹងផែនការដែលត្រូវអនុវត្ត ផ្នែកនេះ សម្រេចបាន លទ្ធផលក្នុងរង្វង់ប្រមាណតែ ៧០% ប៉ុណ្ណោះ ដែលនេះ បញ្ជាក់ឱ្យឃើញថា ផ្នែកទី៤ នេះ ស្ថិតនៅស្ថានភាពមួយពុំទាន់ល្អប្រសើរធៀបនឹងផ្នែកដ៏ទៃទៀត ហើយចាំបាច់ទាមទារឱ្យមានការបន្តពង្រឹងការគាំទ្រដល់ផ្នែកនេះឱ្យបានខ្លាំងក្លា និងសកម្មថែមទៀត ជាពិសេស ការរៀបចំឱ្យប្រសើរជាងមុន និងធ្វើបច្ចុប្បន្នកម្មឯកសារបណ្ដុះបណ្ដាលវិស័យជំនាញឱ្យបានសុក្រឹតថែមទៀត ក៏ដូចជាការរៀបចំបង្កើតសកម្មភាពឱ្យបានមុតស្រួច ក្នុងការគាំទ្រដល់ការបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងការបណ្ដុះឆន្ទៈនៃការកែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវគ្រប់ក្រសួងស្ថាប័ន ដែលចង្កោមសកម្មភាពទាំងពីរនេះស្ថិតនៅស្ថានភាពមួយ ដែលពុំទាន់

របាយការណ៍ខាងក្រោមនេះនឹងមានបញ្ជាក់ជូនលម្អិតអំពីវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅឆ្ពោះទៅមុខតាមគោលបំណងទាំង២។ ដោយហេតុថាគោលបំណងទាំងនេះ ពុំត្រូវបានរំលេចនៅឆ្នាំកន្លង របាយការណ៍នេះនឹងមិន ធ្វើការប្រៀបធៀបអំពីវឌ្ឍនភាពដែលសម្រេចបាននៅឆ្នាំ ២០១៣ ជាមួយនឹងការងារដែលបានអនុវត្តនៅឆ្នាំ ២០១៤ ដូចដែលបានរៀបរាប់ពីខាងលើនោះទេ ។

## ៤.១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្ដុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ

សម្រាប់ឆ្នាំ ២០១៤ នេះ ការបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្ដុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់និង ការទទួលខុសត្រូវ មានចង្កោមសកម្មភាពចំនួន ២ គឺ (១) ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព

គ្រប់គ្រង និង (២) បង្កើនឆន្ទៈកំណែទម្រង់ភាពជាម្ចាស់ និងការទទួលខុសត្រូវ។ ជារួម ផ្អែកលើការអនុវត្តកន្លងមក គោលបំណងនេះសម្រេចបាន ៦០% ក្នុងនោះ ចង្កោមសកម្មភាព ៤១.១ សម្រេចបាន ៤០% និងចង្កោមសកម្មភាព ៤១.២ សម្រេចបាន ៨០%។

ផ្អែកលើលទ្ធផលខាងលើនេះ ឃើញថាសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពគ្រប់គ្រងត្រូវបានបង្កើនតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលា ព្រមទាំងការចូលរួមមានលក្ខណៈផុសផុល ប៉ុន្តែ ធាតុពិតនៃសកម្មភាពដែលបានអនុវត្តពុំទាន់បំពេញតាមគោលដៅនៃគោលបំណងនេះឡើយ។ ក្នុងចំណោម ១២ អគ្គនាយកដ្ឋានចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតែ២ អគ្គនាយកដ្ឋានប៉ុណ្ណោះ ដែលបានបង្កើតកម្មវិធីបណ្តុះបណ្តាលក្នុងគោលដៅពង្រឹងសមត្ថភាពគ្រប់គ្រង និងសមត្ថភាពដឹកនាំ។ ហើយមានតែ១ អគ្គនាយកដ្ឋាន ដែលបានរៀបចំសកម្មភាព និងក្រុមការងារច្បាស់លាស់ សម្រាប់ពង្រឹងឆន្ទៈកំណែទម្រង់ ភាពជាម្ចាស់ និងការទទួលខុសត្រូវតាមរយៈការចូលរួមរបស់អគ្គនាយក-ដ្ឋាន/អង្គភាព ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការរៀបចំផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន/អង្គភាព ឱ្យឆ្លើយតបទៅនឹងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានមួយចំនួនទៀត បានស្ថិតនៅដំណាក់កាលកំពុងបញ្ចប់ប្រកាស សេចក្តីណែនាំ បទដ្ឋានគតិយុត្តនានាក្នុងទិសដៅផ្សព្វផ្សាយផែនការសកម្មភាព កែទម្រង់ និងការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញ។ មានសកម្មភាពច្រើនដើម្បីបម្រើឱ្យផ្នែកនេះ។

## ៤.២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត

គោលបំណងនេះ មានចង្កោមសកម្មភាពគាំទ្រចំនួន ២ សម្រាប់ឆ្នាំ ២០១៤ នេះ (១) ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាពថ្មី និង (២)ពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមក និងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌ និងសង្គតិភាព។ ជារួម ផ្អែកលើការអនុវត្តកន្លងមក គោលបំណងនេះសម្រេចបានក្នុងរង្វង់៨០% ក្នុងនោះ ចង្កោមសកម្មភាព៤២.១ សម្រេចបាន៦២% និង៤២.២ សម្រេចបាន៩៨%។

ផ្អែកតាមលទ្ធផលដែលសម្រេចបានខាងលើនេះ ពុំមានសកម្មភាពណាមួយ ដែលគាំទ្រលើការពិនិត្យឡើងវិញនូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាព សម្រេចបានជាស្ថាពរទេ។ ទោះជាយ៉ាងណាក្តី ក៏នៅមានសកម្មភាពវិជ្ជមានមួយចំនួនរៀបចំបណ្តើរៗក្នុងនោះ គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រសួងស្ថាប័ន កំពុងត្រូវបានពិនិត្យ និងកែលម្អ។ ផ្ទុយពីនេះ សកម្មភាពស្រាវជ្រាវ ឯកសារបណ្តុះបណ្តាល តាមវិស័យជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុវត្តទៅនៅតិចតួចធៀបនឹងផែនការដែលបានដាក់ចេញ។ យ៉ាងណាមិញ សកម្មភាពសម្រាប់គាំទ្រពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមក និងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌ និងសង្គតិភាព ទទួលបានវឌ្ឍនភាពច្រើន ក្នុងនោះសកម្មភាពភាគច្រើនសម្រេចបានទាំងស្រុងតាមផែនការដែលបានគ្រោងទុក ដែលលទ្ធផលទាំងនេះស្តែងចេញតាមរយៈការរៀបចំគណៈកម្មាធិការដើម្បីពិនិត្យ និងវាយតម្លៃដែលទទួលបានករលើកទឹកចិត្ត, ការបង្កើតឱ្យមាន

យន្តការតាមដានសមិទ្ធកម្ម និងជ្រើសរើសមន្ត្រីសម្រាប់ទទួលបានការលើកទឹកចិត្ត ព្រមទាំងពង្រឹកយន្តការដាក់ទណ្ឌកម្ម។

ជារួមការងារកែទម្រង់ត្រូវផ្តោតលើប្រព័ន្ធដែលមានស្រាប់, យន្តការដែលត្រូវដើរ, ក្របខណ្ឌគតិយុត្ត ដែលមានលក្ខណៈសមស្របមិនអាចគ្រប់គ្រាន់សម្រាប់អាចឱ្យការងារនេះដំណើរការបានដោយរលូន និងស័ក្តិសិទ្ធភាពបានទេ ដ៏រាបណាសមត្ថភាពរបស់ស្ថាប័នពុំត្រូវបានពង្រឹង ដើម្បីបណ្តុះ ឆន្ទៈ ការប្តេជ្ញាចិត្ត ភាពជាម្ចាស់ និងការទទួលខុស។ ការងារសម្រាប់ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រង ហាក់នៅពុំទាន់បានអនុវត្តទៅបានប្រសើរនៅឡើយទេ ដែលទាមទារនូវការពង្រឹងការងារជាក់លាក់បន្ថែមទៀតដូចជា÷យុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស,ផែនការផ្សព្វផ្សាយ, ការបណ្តុះបណ្តាលពីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានទូលាយ និងការរៀបចំឱ្យបានប្រសើរជាងមុន និងការធ្វើបច្ចុប្បន្នកម្មនូវឯកសារបណ្តុះបណ្តាលតាមវិស័យជំនាញ។ដើម្បីបន្តពង្រឹងផ្នែកនេះ ទិសដៅជាក់លាក់មួយចំនួនបាននិងកំពុងរៀបចំនៅក្នុងក្របខ័ណ្ឌរួមនៃ CAP 3 ពោលគឺ ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេសភាពជាម្ចាស់ ការទទួលខុសត្រូវ មានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

មេរៀន និងបទពិសោធន៍មួយចំនួនក៏បានបញ្ជាក់ផងដែរ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះពិតជាពុំអាចអនុវត្តទៅដោយគ្មានការគាំទ្រពីក្រសួងស្ថាប័នដទៃទៀតបាននោះទេ ព្រោះក្នុងការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី២ និងទី៣ អង្គភាពដែលត្រូវចូលរួមបង្កើតជាចង្កោមសកម្មភាព/សកម្មភាព ក៏មិនមែនស្ថិតនៅតែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែម្នាក់ឯងសុទ្ធសាធនោះទេ ក្រសួងស្ថាប័ន ទាំងអស់សុទ្ធតែមានចំណែកចូលរួមអនុវត្តក្រោមការ ពិនិត្យតាមដានពីអគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៥.វឌ្ឍនភាពរបស់ ក្រសួង /ស្ថាប័ន

បទពិសោធន៍របស់ក្រសួង ស្ថាប័ន ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអស់រយៈពេលជាង១០ ឆ្នាំកន្លងមកនេះ ថ្វីត្បិតតែគ្រប់ក្រសួង ស្ថាប័ន បានចូលរួមចំណែកពីដំណាក់កាលមួយទៅដំណាក់មួយមែនពិតតែការអនុវត្តនៅពុំទាន់មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ យើងត្រូវទទួលស្គាល់ថាភាពសកម្ម ក៏ដូចជាការទទួលស្គាល់អំពីភាពចាំបាច់ដែលត្រូវចូលរួមចំណែកក្នុងកម្មវិធីដឹកនាំការងារកែទម្រង់នេះនៅមានកម្រិតនៅឡើយ ជាក់ស្តែងក្រសួងស្ថាប័ន ភាគច្រើន ច្រើនរង់ចាំការផ្តល់ទិសដៅ និងការណែនាំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាជាងដែលក្រសួង ស្ថាប័នទាំងនេះខិតខំពង្រឹងដោយខ្លួនឯង និងស្វែងរកចំណុចដែលត្រូវកែលម្អ ដែលកត្តាទាំងនេះធ្វើឱ្យកម្មវិធីកែទម្រង់ទាំងមូលជួបបញ្ហាប្រឈមជាច្រើន និងអនុវត្តទៅមានការយឺតយ៉ាវ។

ក្នុងដំណាក់កាលនៃចំណុចរបត់ ជាពិសេស ការបញ្ចប់ដំណាក់កាលទី២ ឈានទៅដំណាក់កាលទី៣ យើងក៏ឈានមកដល់ចំណុចផ្លាស់ប្តូរដ៏សំខាន់មួយផងដែរ ពោលគឺការងារកែទម្រង់ត្រូវបានផ្ទេរពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង ស្ថាប័ននានា ដែលធ្វើឱ្យទម្ងន់ការងារក៏ត្រូវបានផ្ទេរផងដែរ។

តាមរយៈរបាយការណ៍ដែលក្រសួង ស្ថាប័នបានរៀបចំឃើញថា ភាពជាម្ចាស់និងការទទួលខុសត្រូវនៅមានកម្រិតនៅឡើយ ជាក់ស្តែង របាយការណ៍បានរំលេចពីការងារប្រចាំថ្ងៃច្រើនជាងការងារកែទម្រង់ ដែលនេះបង្ហាញឱ្យឃើញអំពីការមិនទាន់ញែកឱ្យដាច់ពីគ្នាអំពីការងារប្រចាំថ្ងៃ និងការងារកែទម្រង់។ ក្រៅពីនេះ មានកិច្ចការជាច្រើនបាននិងកំពុងអនុវត្តពុំមានភាពរលូនដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកា និងកត្តាធនធានមនុស្ស ជាដើម។ ដោយឡែកក្នុងផែនការសកម្មភាពដែលរៀបចំឡើងដោយក្រសួងស្ថាប័ន សម្រាប់កែលម្អ និងដើម្បីអាចក្រសួងស្ថាប័នអនុវត្តទៅបានប្រសើរជាងមុន ពុំបានរំលេចអំពីការងារចាំបាច់ ដែលត្រូវកែលម្អនោះទេ។

## III. បញ្ហាប្រឈម

ដូចបានគូសបញ្ជាក់ពីខាងដើមហើយថា ការអនុវត្តកម្មវិធីកែទម្រង់នៅក្នុងឆ្នាំនីមួយៗ រមែងប្រព្រឹត្តទៅដោយមានកង្វះខាតជាប់មកជាមួយជាប្រចាំ ធ្វើឱ្យកម្មវិធីកែទម្រង់ទាំងមូលពុំអាចប្រព្រឹត្តទៅដោយរលូនបានជាប្រចាំនោះទេ។ បញ្ហាប្រឈមដែលត្រូវបានរំលេចឡើងតាំងពីឆ្នាំ២០១៣ ក៏ត្រូវបានប្រទះឃើញឡើងវិញជារើយៗ បន្តទៀតក្នុងឆ្នាំ ២០១៤ នេះ។ បន្ថែមពីនេះ ក៏នៅមានបញ្ហាប្រឈមជាបច្ចេកទេសដ៏ទៃទៀត ដូចមានគូសបញ្ជាក់ដូចខាងក្រោមនេះ÷

- □ការអនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំពុំទាន់មានភាពសុក្រឹត និងសមត្ថភាពព្យាករណ៍ (ក្នុងឆ្នាំ) ហាក់ នៅមានកម្រិត
- □ការរៀបចំសកម្មភាព និងការកំណត់សូចនាករ មិនទាន់មានសុក្រឹតភាព និងសង្គតិភាពទៅនឹងចង្កោមសកម្មភាព និងគោលបំណងដែលបានកំណត់
- □ទទួលស្គាល់ថាវិធិសាស្ត្រវាស់វែងលទ្ធផលតាមសកម្មភាព នៅពុំទាន់មានរូបមន្តជាលក្ខណៈវិទ្យាសាស្ត្រ
- □ដោយសមត្ថភាពមន្ត្រីនៅមានកម្រិត ការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំ**<u>ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ</u> ពុំទាន់បានអនុវត្ត**តាមផែនការ
- □ការអនុវត្ត**<u>ផែនការចំណូល និងចំណាយក្នុងឆ្នាំពុំទាន់មានភាពសុក្រឹត</u>**និង**<u>សមត្ថភាពព្យាករណ៍</u>**(ក្នុងឆ្នាំ )ហាក់នៅមានកម្រិត
- □ក្រសួងទាំង ១០ ដែលត្រូវអនុវត្តសាកល្បងអង្គភាពថវិកា ពុំទាន់ទទួលបានការណែស្តីពីនីតិវិធីអនុវត្តលម្អិតច្បាស់លាស់ ដែលអាចជាបញ្ហាប្រឈមក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងឆ្នាំ ២០១៥
- □ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដែលការរៀបចំ Training Need Assessment អាចឱ្យយើងដឹងពីតម្រូវការពិតប្រាកដ នៃការបណ្តុះបណ្តាល
- □ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានមួយចំនួន ពុំបានរៀបចំប្រជុំប្រចាំខែ និងប្រចាំត្រីមាស ដើម្បីតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាព និងបញ្ហាប្រឈក្នុងការអនុវត្តកម្មវិធីកែទម្រង់របស់ខ្លួន។

## IV. អនុសាសន៍

ក្នុងការអនុវត្តកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងមូលក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាជាជំហានៗ ឆ្ពោះទៅរកស្តង់ដារអន្តរជាតិ ស្របតាមទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ឆ្នាំ ២០១៣-២០២០ ពិតជាមានការលំបាក ។ ជាក់ស្តែង សម្រាប់ការអនុវត្តនៅឆ្នាំ ២០១៤ នេះ បញ្ហាប្រឈម រួមទាំងដំណោះស្រាយមួយចំនួនត្រូវបានរៀបចំដោះស្រាយ ដើម្បីស្តារស្ថានភាពសម្រាប់ការអនុវត្តនៅជំហានបន្ទាប់។ សម្រាប់កំណត់កត្តាជោគជ័យ ចំណុចដូចរៀបរាប់ជូនខាងក្រោមនេះ គួរត្រូវបានយកចិត្តទុកដាក់ និងកំណត់ជាកត្តាអទិភាពជាមូលដ្ឋានក្នុងការអនុវត្តកម្មវិធីកែទម្រង់នេះបានទៅដោយរលូនពីមួយឆ្នាំទៅមួយឆ្នាំ ÷

- □គួរបង្កើន សុក្រឹតភាព នៃការអនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំ និងសមត្ថភាពព្យាករណ៍ (ក្នុងឆ្នាំ)ដែលនៅមានកម្រិត
- □គួររៀបចំសកម្មភាព និងការកំណត់សូចនាករ ឱ្យមានសុក្រឹតភាព និងសង្គតិភាពទៅនឹងចង្កោមសកម្មភាព និងគោលបំណងដែលបានកំណត់
- □គួរពង្រឹងការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំ<u>**ផែនការយុទ្ធសាស្រ្តថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**</u>តាមសកម្មភាព និងការកំណត់សូចនាករ
- □គួររៀបចំសេចក្តីណែនាំណែស្តីពីនីតិវិធីអនុវត្តលម្អិត ច្បាស់លាស់សម្រាប់ ក្រសួងទាំង ១០ ដែលត្រូវអនុវត្តសាកល្បងអង្គភាពថវិកា និងអាចអនុវត្តប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងឆ្នាំ ២០១៥
- □គួរពង្រឹងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការកសាងសមត្ថភាព តាមរយៈការរៀបចំ Training Need Assessment
- □ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានមួយចំនួន ពុំបានរៀបចំប្រជុំប្រចាំខែ និងប្រចាំត្រីមាស គួររៀបចំប្រជុំជាប្រចាំដើម្បីតាមដាន និងវាយតម្លៃ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីកែទម្រង់របស់ខ្លួន។

បញ្ហាប្រឈមនេះ ត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាការដឹកនាំការងារកែទម្រង់កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញជាវិធានការមួយចំនួន ដើម្បីកែលម្អស្ថានភាពទាំងនេះភ្លាមៗ។ ជាលទ្ធផលការងារមួយចំនួនត្រូវបានអគ្គនាយកដ្ឋានពាក់ព័ន្ធបានរៀបចំសកម្មភាព និងពង្រឹងការអនុវត្តនូវកិច្ចការចាំបាច់មួយចំនួនដូចតទៅ÷

១. ពាក់ព័ន្ធនឹងការជំរុញការដាក់ឱ្យ**អនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព**ដើម្បីបម្រើឱ្យប្រសិទ្ធភាពនៃប្រព័ន្ធ និងយន្តការត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការអនុវត្តថវិកា អគ្គនាយកដ្ឋានពាក់ព័ន្ធបានរៀបចំជាសកម្មភាព និងបានកំណត់សូចនាករ ព្រមទាំងរៀបចំជាសកម្មភាពអនុវត្តជាបណ្តើរៗ ទោះបីជាលទ្ធផលភ្លាមៗពុំទាន់អាចវាយតម្លៃបាននៅឡើយក៏ពិតមែន។

២. ចំពោះចំណុចដែលពាក់ព័ន្ធនឹងការពង្រឹងលើកិច្ចការការអនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំពុំទាន់មានភាពសុក្រឹត្យ និងសមត្ថភាពព្យាករណ៍ (ក្នុងឆ្នាំ )ហាក់នៅមានកម្រិត ជាវិធានការឃើញថា អង្គភាពប្រមូល

ចំណូលបានរៀបចំសកម្មភាពសម្រាប់គាំទ្រការរៀបចំម៉ូដែលព្យាករណ៍ចំណូល (សម្រាប់ពន្ធដារ ចាប់ផ្តើមត្រីមាសទី១, គយចាប់ផ្តើមត្រីមាសទី២, ទ្យព្យសម្បត្តិរដ្ឋត្រីមាសទី៣ និងឧស្សាហកម្មហិរញ្ញវត្ថុត្រីមាសទី២)

៣. ពាក់ព័ន្ធនឹងការពង្រឹងការរៀបចំនិង**ការអនុវត្តផែនការយុទ្ធសាស្ត្រសថវិកា** ដើម្បីបង្កើនភាពគ្រប់ជ្រុងជ្រោយនៃថវិកាអគ្គនាយដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសារាចរស្តីពីផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំត្រូវបានកែលម្អ និងរៀបចំរួច ដើម្បីធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត ថវិកាមូលធន និងគ្រឹះស្ថានសាធារណៈ និងគោលការណ៍ណែនាំស្តីអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវបានកំពុងកែលម្អឱ្យស្របតាមការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៣-២០២០

៤. ចំពោះអគ្គនាយកដ្ឋានដែលទទួលបន្ទុកកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យមានការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្នុងករណីចាំបាច់គួរស្នើសុំជំនួយបច្ចេក-ទេសបន្ថែមពីអគ្គនាយកដ្ឋានថវិកា ឬ អគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះ អគ្គនាយកដ្ឋានបានរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានកិច្ចសហការពីអង្គភាពពាក់ព័ន្ធ

៥.ចំពោះក្រសួងទាំង១០ ដែលត្រូវអនុវត្តសាកល្បងអង្គភាពថវិកា ហើយពុំទាន់ទទួលបានការណែនាំស្តីពី នីតិវិធីអនុវត្តលម្អិត ច្បាស់លាស់ ដែលអាចជាបញ្ហាប្រឈមក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាព និង គណនេយ្យភាពក្នុងឆ្នាំ២០១៥ នោះ អគ្គនាយដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំ និង ដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីនៅខែមករា ឆ្នាំ២០១៥

៦.សម្រាប់អគ្គនាយកដ្ឋានលទ្ធកម្ម ដែលតម្រូវឱ្យមានរៀបចំប្រជុំ ដើម្បីយល់ពីខ្លឹមសារសេចក្តីព្រាងនីតីវីធីលទ្ធកម្ម និងធ្វើការកែលម្អឱ្យបានត្រឹមត្រូវ រួចធ្វើការបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកឱ្យ យល់ច្បាស់ ទាំងមន្ទីរឱ្យយល់ដឹងពីការងារទាំងនោះ

## V. សន្និដ្ឋាន

ជាការសន្និដ្ឋានជារួម និងឆ្លងតាមបទពិសោធន៍នាពេលកន្លងមក រៀងរាល់ការសម្រេចចិត្តឈានទៅបញ្ចប់ពីដំណាក់កាលមួយដើម្បីឆ្លងទៅដំណាក់កាលមួយទៀត អាចអនុវត្តទៅបានដោយរលូន គឺអាស្រ័យលើការសម្រេចបាននូវលទ្ធផលការងារសំខាន់ៗតាមផ្នែកនីមួយៗ ដែលបានដាក់ចេញនៅក្នុងជំហាន/ដំណាក់កាលនីមួយៗជាពិសេស ទន្ទឹមនឹងការបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាឆ្ពោះទៅរកប្រព័ន្ធរឹងមាំ និងប្រកបដោយស្ថិរភាពនោះ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុជាសារវន្តក៏ត្រូវតែសម្រេចឱ្យបាន ទើបអាចឈានទៅដំណាក់កាលទី៣ គឺការបង្កើនការ ផ្សារភ្ជាប់ ថវិកាទៅនឹងគោលនយោបាយ។ នៅក្នុងការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី២ ថ្មីនេះ ការបន្តពង្រឹង និងពង្រីកការអនុវត្តសាកល្បងថវិកាកម្មវិធី និងការបង្កើនភាពគ្រប់ជ្រង់ជ្រោយ និងសមាហរណកម្មថវិកា ដែលជាការត្រៀមលក្ខណៈសម្រាប់ជំហានទី៣។ យោងតាមរបាយការណ៍វាយនេះ យើងអាចស្និដ្ឋានជារួមបានថា÷

**១. *ភាពជឿទុកចិត្តបាននៃថវិកា*** ផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះទាំង ៥ ឃើញថាគម្លាតចំណូល និងចំណាយថវិកាជាតិកាន់តែតូចធៀបនឹងច្បាប់ថវិកា ដែលបានអនុម័ត, លំហូរចំណូល និងចំណាយថវិកានេះក៏កាន់តែរលូន, ការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានស្ទើរតែទាំងស្រុងនូវបញ្ហាបំណុលកកស្ទះ ។ ផ្អែកតាម លទ្ធផលនៃចង្កោមសកម្មភាព ផ្នែកនេះសម្រេចបាន ៨៥% មានន័យថា សកម្មភាពសម្រាប់បន្តពង្រឹងផ្នែកភាពជឿ ទុកចិត្តបាននៃថវិកាបាននិងកំពុងអនុវត្តទៅបានប្រសើរ ផងដែរ។ ជាទូទៅ ភាពជឿទុកចិត្តបាននៃថវិកាអាចរក្សាបាន ជាសារវន្ត ប៉ុន្តែចាំបាច់ត្រូវការមានការពង្រឹងលើកិច្ចការចាំបាច់មួយចំនួន ជាពិសេស ប្រសិទ្ធភាពនៃការរៀបចំ និងការ អនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំពុំទាន់មានភាពសុក្រឹត និងសមត្ថភាពព្យាករណ៍ (ក្នុងឆ្នាំ) ហាក់នៅមាន កម្រិត។ ទន្ទឹមនេះ ការគ្រប់គ្រងសាច់ប្រាក់ក៏ទាមទារឱ្យមានការពង្រឹងបន្ថែម ជាពិសេសលើប្រព័ន្ធ និងយន្តការ។ ថ្វីត្បិតតែពុំមានបំណុលកកស្ទះ (ស្តង់ដារ៩០ ថ្ងៃ) ប៉ុន្តែការឈានទៅធានាស្ថិរភាព និងភាពជឿទុកចិត្ត បាននៃ ថវិកា លុះត្រាមានយន្តការកត់ត្រា និងប្រព័ន្ធរបាយការណ៍ច្បាស់លាស់ និងទាន់ពេលវេលាលើបំណុលកកស្ទះ (ទាំង បំណុលត្រូវទា និងត្រូវសង)។

**២. ចំពោះគណនេយ្យភាពហិរញ្ញវត្ថុ** ជារួមផ្អែកតាមលទ្ធផលចង្កោមសកម្មភាពដែលសម្រេចបាន ៧៥% យើងអាចសន្និដ្ឋានបានថា កិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួន ជាពិសេស សមាសធាតុចាំបាច់ អាចយកមកប្រើប្រាស់បានសម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) បានទាន់ពេលវេលាតាមកាល កំណត់។ អ្វីដែលជាការព្រួយបារម្ភនោះគឺការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព ជាពិសេស ចំពោះក្រសួងស្ថាប័ន១០ ដែលអនុវត្តថវិកាកម្មវិធីពេញលេញ ពុំទាន់ត្រូវបានរៀបចំជាសកម្មភាពឱ្យបានជាក់លាក់។

**៣. *សម្រាប់ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់*** ជារួមផ្អែកតាមលទ្ធផលចង្កោមសកម្មភាពដែលសម្រេចបាន ៨២% ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់សម្រេចបានការងារច្រើន តែចាំបាច់ត្រូវខិតខំពង្រឹងការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំគោលនយោបាយ វិមជ្ឈការហិរញ្ញវត្ថុ សម្រាប់រយៈពេលមធ្យម និងវែង និងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីគួរត្រូវបានយកចិត្តទុកដាក់ និងពង្រឹងសកម្មភាពអនុវត្ត។

៤. សម្រាប់ផ្នែកចុងក្រោយគឺ**ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព** ជារួម ផ្អែកតាមលទ្ធផលចង្កោមសកម្មភាពផ្នែកនេះសម្រេចបាន៧០% ដែលជាការកត់សម្គាល់ ក្នុងចំណោមផ្នែកទាំង៤ ផ្នែក នេះសម្រេចបានទាបជាងគេ នោះបញ្ជាក់អំពីភាពចាំបាច់ក្នុងការបន្ត និងពង្រឹងការគាំទ្រដល់ផ្នែកនេះ បន្ថែមទៀត ជាពិសេស យុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ផែនការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលពីសកម្មភាពកែទម្រង់ ឱ្យបានទូលាយ, ការរៀបចំឱ្យប្រសើរជាងមុន និងធ្វើបច្ចុប្បន្នកម្មនូវឯកសារបណ្តុះបណ្តាលវិស័យជំនាញ។ គួររៀបចំបង្កើតសកម្មភាពឱ្យបានជាក់លាក់បន្ថែមទៀត៕